

# សេចក្តីថ្លែងការណ៍ និងការអធិប្បាយ
# របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា
# ស្តីពីផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា
# និង សាធារណរដ្ឋសង្គមនិយមវៀតណាម

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥

*“... ការលើកយកបញ្ហាព្រំដែននេះ មកធ្វើជាអាជីវកម្មកេងចំណេញ ខាងនយោបាយដោយគ្មានការទទួលខុសត្រូវ ដើម្បីបម្រើឱ្យផលប្រយោជន៍នយោបាយរបស់បុគ្គលណាម្នាក់ ក្រុមណាមួយ ឬគណបក្សណាមួយ តាមរយៈការប្រើមធ្យោបាយប្រជាភិថុត ដើម្បីបំភាន់សាធារណមតិជាតិ និងអន្តរជាតិ អាចនឹងនាំមកនូវគ្រោះថ្នាក់ធំធេងដល់ប្រទេសជាតិ និងប្រជាជនទៅវិញទេ ...”*

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

**សេចក្ដីថ្លែងការណ៍**

ដើម្បីផ្ដល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា ស្ដីពីផែនទីព្រំដែនរដ្ឋ
រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍ និងការអធិប្បាយ
# របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា
# ស្តីពីផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា
# និង សាធារណរដ្ឋសង្គមនិយមវៀតណាម

**រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥**

*- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈជាទីសក្ការៈ*

*- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ*

*- ជនរួមជាតិកម្ពុជាគ្រប់រូបជាទីគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត!*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីត្រូវការដ៏ចាំបាច់ក្នុងការធ្វើនូវសេចក្តីថ្លែងការណ៍ ដើម្បីបំភ្លឺប្រគេន និងជូនដល់ព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិគ្រប់រូប អំពីផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានក្លាយជាប្រធានបទនយោបាយដ៏ក្តៅគគុក ប្រកបដោយគ្រោះថ្នាក់សម្រាប់ប្រទេសជាតិនាពេលថ្មីៗនេះ។ ជាការពិត បញ្ហាព្រំដែនគឺជាកិច្ចការដ៏មានសារសំខាន់ជាអាយុជីវិតរបស់ប្រទេសជាតិ ហើយក៏ជាបញ្ហានយោបាយដ៏រសើបបំផុត ដែលអ្នកនយោបាយមួយចំនួនតែងលើកយកមកធ្វើជាប្រធានបទសម្រាប់ឃោសនាញុះញង់ឥតឈប់ឈរ តាមរយៈមធ្យោបាយប្រជាភិថុតនានា ដើម្បីបំភាន់សាធារណមតិជាតិ និងអន្តរ

ជាតិ ហើយអូសទាញបោកបញ្ឆោតទឹកចិត្តស្នេហាជាតិ ពិតប្រាកដរបស់បងប្អូនជនរួមជាតិខ្មែរ ដើម្បីវាយប្រហារមកលើរាជរដ្ឋាភិបាលក្នុងគោលបំណងកេងចំណេញយកផលប្រយោជន៍ខាងនយោបាយ។

ច្បាស់ណាស់ថា ការស្នេហាជាតិនិងទឹកដី គឺពុំមែនជាសិទ្ធិផ្តាច់មុខរបស់បុគ្គល ឬគណបក្សនយោបាយ ណាមួយតែឯងនោះទេ។ កិច្ចការពារអធិបតេយ្យ និងបូរណភាពទឹកដីរបស់ជាតិ គឺជាសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ហើយរាជរដ្ឋាភិបាលតែងបានចាត់ទុកការងារនេះជាភារកិច្ច និងកាតព្វកិច្ចជាអាទិភាពដ៏សំខាន់ជាងគេបង្អស់របស់ខ្លួន និងតែងប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវស្មារតីទទួលខុសត្រូវខ្ពស់បំផុតក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីកសាងខ្សែបន្ទាត់ព្រំដែនមួយ ដែលមានភាពច្បាស់លាស់ ត្រឹមត្រូវ ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ជាមួយប្រទេសជិតខាង និងធានាឱ្យបានជាដាច់ខាតថា បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជានឹងមិនបាត់បង់ឡើយ សូម្បីតែមួយម៉ែត្រក្រឡា ក៏ដោយ។

ក្នុងស្មារតីនេះ ក៏ដូចជាក្នុងគោលដៅគូសបញ្ជាក់ឱ្យឃើញច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នៅក្នុងការដោះស្រាយបញ្ហានេះ ក្នុងឋានៈជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៤ នៃរដ្ឋសភា ខ្ញុំព្រះករុណាខ្ញុំបានចំណាយពេលអស់ជាង ៥ ម៉ោង ដើម្បីធ្វើបទអន្តរាគមន៍បកស្រាយ និងផ្តល់ការបំភ្លឺគ្រប់ជ្រុងជ្រោយជូនដល់រដ្ឋសភា និងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសអំពីការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្ររវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២។ ក៏ប៉ុន្តែ ថ្វីត្បិតតែមានការបកស្រាយពន្យល់ច្បាស់លាស់រួច

ហើយ ហើយបទអន្តរាគមន៍នោះក៏ត្រូវបានយកមករៀបចំបោះពុម្ពចែកផ្សាយជាសៀវភៅផង និងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមបណ្តាញអ៊ីនធើណិត និងបណ្តាញព័ត៌មាននានាផងក្តី ក៏អ្នកនយោបាយប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួននៅតែបន្តធ្វើជាមិនយល់ដដែល។ លើសពីនេះទៀត ពួកគេបាននិងកំពុងបន្តឃោសនាបំផុសបំផុល បំភ្លៃបំផ្លើស និងកែកាឡៃការពិតនិងសភាពការណ៍ទាក់ទងនឹងបញ្ហាព្រំដែនកម្ពុជាជាមួយវៀតណាម ប្រកបដោយឧបាយកលនយោបាយទុច្ចរិតឥតអៀនខ្មាស ក្នុងគោលដៅបង្កើតឱ្យមានការភាន់ច្រឡំ និងការយល់ដឹងមិនត្រឹមត្រូវលើបញ្ហាព្រំដែននេះ ហើយបោកបញ្ឆោតធ្វើអាជីវកម្មលើទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនប្រជាពលរដ្ឋខ្មែរចំពោះជាតិមាតុភូមិជាទីស្នេហារបស់ខ្លួន ដើម្បីកេងយកផលចំណេញនយោបាយ ដោយមិនខ្វាយខ្វល់ និងគ្មានការទទួលខុសត្រូវចំពោះជោគវាសនា និងផលប្រយោជន៍របស់ប្រទេសជាតិឡើយ ។ ជាការពិត ប្រវត្តិសាស្ត្រតំបន់ និងពិភពលោក ជាពិសេសបទពិសោធន៍ផ្ទាល់របស់កម្ពុជាបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ហើយថា ការលើកយកបញ្ហាព្រំដែននេះ មកធ្វើជាអាជីវកម្មកេងចំណេញខាងនយោបាយដោយគ្មានការទទួលខុសត្រូវ ដើម្បីបម្រើឱ្យផលប្រយោជន៍នយោបាយរបស់បុគ្គលណាម្នាក់ ក្រុមណាមួយ ឬគណបក្សណាមួយ តាមរយៈការប្រើមធ្យោបាយប្រជាភិថុត ដើម្បីបំភាន់សាធារណមតិជាតិ និងអន្តរជាតិ អាចនឹងនាំមកនូវគ្រោះថ្នាក់ធំធេងដល់ប្រទេសជាតិ និងប្រជាជនទៅវិញទេ ជាពិសេសការបែកបាក់សាមគ្គីជាតិ និងឯកភាពជាតិ ការបង្កអរិភាពជាតិសាសន៍ និងការបង្កការខូចខាតដល់ទំនាក់ទំនងមិត្តភាព សហប្រតិបត្តិការ និងអ្នកជិតខាងល្អរវាងប្រទេសជិតខាងជាប់ព្រំដែនគ្នា។

យ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ គណបក្សប្រឆាំង តាមរយៈអ្នកនយោបាយមួយចំនួនរបស់ខ្លួនបានលើកយកបញ្ហាព្រំដែននេះមកធ្វើជាអាជីវកម្មនយោបាយជាថ្មីម្តងហើយម្តងទៀត ដោយធ្វើការចោទប្រកាន់ និងមួលបង្កាច់ក្នុងលក្ខណៈកាន់តែស្រួចស្រាវ និងកាន់តែពិសពុល ដោយមិនខ្លាចញញើត ច្បាប់រដ្ឋ និងគ្មានស្មារតីទទួលខុសត្រូវបន្តិចណាទាល់តែសោះ។ ពួកគេបានចោទប្រកាន់ដោយមួលបង្កាច់មកលើរាជរដ្ឋាភិបាលថា បានប្រើប្រាស់ផែនទីក្លែងក្លាយ ឬផែនទីមិនត្រឹមត្រូវ ឬ "**ផែនទីចោរ**" ក្នុងការកំណត់ព្រំដែនជាមួយប្រទេសវៀតណាម ហើយថែមទាំងបានលើកយកសន្ធិសញ្ញាឆ្នាំ ១៩៧៩ ក្លែងក្លាយមកប្រើប្រាស់ដោយឥតញញើត ដើម្បីចោទប្រកាន់យ៉ាងអយុត្តិធម៌បំផុតមកលើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ពិសេសថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជាថា បានសម្រេចរំលាយព្រំដែនជាតិជាមួយប្រទេសវៀតណាម ក្នុងគោលដៅញុះញង់បង្កើតកំហឹងក្នុងចំណោមប្រជាពលរដ្ឋបង្កនូវការបែកបាក់សាមគ្គីជាតិនិងឯកភាពជាតិ ព្រមទាំងបង្កអរិភាពជាតិសាសន៍ដែលអាចបណ្តាលឱ្យមានភាពរីករាលធ្ងន់ធ្ងរដល់សន្តិសុខសង្គម ប្រសិនបើមិនត្រូវបានទប់ស្កាត់ទាន់ពេលវេលានោះទេ។

(សេចក្តីអធិប្បាយបន្ថែម)

*ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ បងប្អូនជនរួមជាតិជាទីស្រលាញ់ ខ្ញុំព្រះករុណាខ្ញុំសូមបកស្រាយចំពោះបញ្ហានេះបន្តិច ប្រគេនចំពោះព្រះសង្ឃ ក៏ដូចជាបងប្អូនជនរួមជាតិថា ប្រសិនបើការក្លែងបន្លំទាក់ទិនជាមួយនឹងបញ្ហាការក្លែងសន្ធិសញ្ញាឆ្នាំ ១៩៧៩ ដែលថាកម្ពុជានិងវៀតណាម សម្រេចរំលាយព្រំដែនជាតិជាមួយប្រទេសវៀតណាមនោះ, កម្ពុជា-វៀតណាម*

នោះ តើផលវិបាកវានឹងកើតមានអ្វីខ្លះ? ប្រសិនបើយើងមិនចាត់វិធានការភ្លាមៗ ទាន់ពេល តាមរយៈនៃការអនុវត្តវិធានការច្បាប់ទៅលើសមាជិកព្រឹទ្ធសភាម្នាក់ ហើយឥឡូវនេះ គូកនរបស់គេកំពុងគេចខ្លួនទៅកាន់ប្រទេសថៃ ហើយយើងក៏កំពុងស្វែងរកដើម្បីយកពួកគេមកទទួលទោសតាមផ្លូវច្បាប់។ ខ្ញុំព្រះករុណាខ្ញុំប៉ាន់ស្មានថា ប្រសិនបើមិនចាត់ការបន្ទាន់ ហើយរកមិនឃើញទុកឱ្យមានការសាបព្រួសនូវល្បិចដ៏គ្រោះថ្នាក់នេះ ទឹកចិត្តស្នេហាជាតិដ៏បរិសុទ្ធរបស់ប្រជាពលរដ្ឋ ត្រូវបានពុះកញ្ជ្រោលឡើង។ ពេលនោះអាចនិយាយបានថា សង្គ្រាមផ្ទៃក្នុងក៏អាចកើត និងសង្គ្រាមទល់ដែនក៏អាចកើត។ ករណីនេះ មានឧទាហរណ៍ កាលពីឆ្នាំ ២០០៨ នៅក្នុងព្រះរាជាណាចក្រថៃ មានក្រុមនិយមជ្រុលមួយក្រុម ទាំងអ្នកនយោបាយ និងក្រុមអ្នកបម្រើនយោបាយ គេបានយកបញ្ហាព្រះវិហារ ជាចំណាប់ខ្មាំងខាងនយោបាយ មិនខុសពីអ្នកនយោបាយនៅកម្ពុជាដែលបានប្រើប្រាស់បញ្ហាព្រំដែនកម្ពុជា-វៀតណាម ជាចំណាប់ខ្មាំងខាងនយោបាយ ដើម្បីបំផ្លាញបក្សកាន់អំណាចនោះទេ។ ជាលទ្ធផល មកដល់ពេលនេះគឺ ក្នុងប្រទេសថៃមានការបែកបាក់មិនទាន់ដល់ទីបញ្ចប់ទេ។ ជម្លោះផ្ទៃក្នុងរវាង លឿង-ក្រហម និងចម្រុះពណ៌ រហូតដល់រដ្ឋប្រហារយោធា មិនទាន់ត្រូវបានដោះស្រាយនៅក្នុងប្រទេសថៃនៅឡើយ។ សង្គ្រាមទល់ដែនជាមួយកម្ពុជាពីឆ្នាំ ២០០៨ រហូតដល់ ២០១១ ទើបតែត្រូវបានបញ្ចប់ តាមរយៈសាលដីកាតុលាការឡាអេ ឆ្នាំ២០១៣តែប៉ុណ្ណោះ។ នេះហើយជាលទ្ធផលនៃភាពនិយមជ្រុល។ នៅក្នុងប្រទេសណាក៏ដោយ បើមានស្ថានភាព

បែបនេះ គឺវាច្បាស់ជាបានកើតរឿងរ៉ាវប្រហាក់ប្រហែលគ្នា។

ខ្ញុំព្រះករុណាខ្ញុំ សូមទូលប្រគេនចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិឱ្យបានជ្រាបថា កុំថាឡើយដល់ទៅរដ្ឋអធិបតេយ្យ សូម្បីតែរដ្ឋក្រោមអាណានិគម រហូតទៅដល់កុលសម្ព័ន្ធ ក៏សុទ្ធតែមានការកំណត់ព្រំប្រទល់ដូចគ្នា។ យើងជារដ្ឋអធិបតេយ្យ គឺមានព្រំដែនរដ្ឋតាំងពីពេលដែលក្រោយបានឯករាជ្យ សម្ដេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គបានខិតខំធ្វើការតស៊ូទាក់ទងលើបញ្ហាព្រំដែននេះ។ ទោះបីជាមុនបានឯករាជ្យ នៅក្រោមអាណានិគមនិយមបារាំង នៅពេលនោះ ក៏មានការបែងចែកជាព្រំដែនរដ្ឋ រវាងយើងជាមួយថៃ, រវាងយើងជាមួយនឹងឡាវ, រវាងយើងជាមួយកូសាំងស៊ីន, ហើយនិងមួយភាគនៃព្រំប្រទល់រដ្ឋបាល រវាងយើងជាមួយនឹងវៀតណាម។

[...] កុំនិយាយដល់រដ្ឋ ហើយកុំនិយាយដល់កុលសម្ព័ន្ធកាលពីសម័យដើម សូម្បីតែនៅក្នុងប្រទេសមួយ ក៏មានព្រំប្រទល់ខេត្ត ព្រំប្រទល់ស្រុក ព្រំប្រទល់ឃុំ ព្រំប្រទល់ភូមិ ហើយក្រុមគ្រួសារនីមួយៗសុទ្ធតែមានប្លង់ដីរឹង ផងដែរ។ ចុះហេតុអ្វី បានជាអ្នកនយោបាយក្នុងបក្សប្រឆាំងមិនញញើតញញើម ហើយហ៊ានបង្ហោះចេញ នូវឯកសារក្លែងក្លាយថា កម្ពុជានិងវៀតណាម បានឯកភាពគ្នារំលាយចោលនូវព្រំដែនរដ្ឋ? នេះជាគ្រោះថ្នាក់ ដ៏ធំធេង បើសិនជារាជរដ្ឋាភិបាលមិនចាត់វិធានការបន្ទាន់។ សង្គ្រាមផ្ទៃក្នុងនឹងអាចផ្ទុះឡើង តាមរយៈនៃស្មារតី ស្នេហាជាតិដ៏បរិសុទ្ធរបស់ជនជាតិខ្មែរយើង រាប់ទាំងខ្ញុំព្រះករុណាខ្ញុំ ក៏ប្រឆាំងជំទាស់

*ជាមួយនឹងការរំលាយ ព្រំដែនរដ្ឋដែរ ប្រសិនវាមានមែន។ ក៏ប៉ុន្តែរឿងនេះវាអត់ទាល់តែសោះ ហើយចុងសតវត្សរ៍ទី២០ ទៅហើយ តើវាអាចមានរឿងនេះកើតឡើងឬទេ? ដូច្នេះ ការចាត់វិធានការបន្ទាន់, ឥឡូវយើងកំពុងស្វែងរកនូវការបង្ហោះតាមហ្វេសប៊ុកមួយចំនួនផ្សេងទៀតដែលទាក់ទងនឹងការបំភ្លៃទៅលើរឿងនេះ ហើយក៏សូមអំពាវនាវអ្នកដែលកំពុងភៀសខ្លួនទៅកាន់ទីក្រុងបាងកក សូមវិលត្រលប់មកទីក្រុងភ្នំពេញ ដើម្បីចូលខ្លួនសម្រាប់សារភាពជាមួយអាជ្ញាធរ ដែលខ្លួនបានរួមគំនិតបង្ហោះចេញនូវហ្វេសប៊ុករបស់សមាជិកព្រឹទ្ធសភារូបនេះ។*

ចំពោះមុខឧបាយកលនយោបាយដ៏ទុច្ចរិតនេះ និងក្នុងបំណងបញ្ចៀសកុំឱ្យបងប្អូនប្រជាពលរដ្ឋខ្មែរចាញ់ ឧបាយកលបោកបញ្ឆោតរបស់អ្នកនយោបាយអគតិទាំងនេះ ហើយក្លាយទាំងមិនដឹងខ្លួនទៅជាឧបករណ៍អាជីវកម្មនយោបាយរបស់គេ ដោយសារតែទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូន រាជរដ្ឋាភិបាលកម្ពុជាដែលតែង ប្រកាន់ខ្ជាប់នូវឆន្ទៈស្នេហាជាតិ ស្មារតីនៃការទទួលខុសត្រូវខ្ពស់និងការប្តេជ្ញាចិត្តដ៏មោះមុតឥតងាករេក្នុងការធានា ការពារឱ្យបានជាដាច់ខាតនូវអធិបតេយ្យជាតិនិងបូរណភាពទឹកដី បានចាត់វិធានការបន្ទាន់ និងចាំបាច់នានា ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ទាំងទិដ្ឋភាពច្បាប់ បច្ចេកទេស និងនយោបាយការទូត ដើម្បី ៖

ទី១ - ធានាតម្លាភាពចំពោះប្រជាជាតិកម្ពុជាទាំងមូល និងបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត អំពីភាព ហ្មត់ចត់ ភាពត្រឹមត្រូវពិតប្រាកដ និងការទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការរៀបចំ និងការអនុវត្តន៍ការងាររបស់ខ្លួន ក្នុងការកំណត់ និងការបោះបង្គោលព្រំ

ដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងប្រទេសជិតខាង

ទី២ - បញ្ចៀស និងបញ្ឈប់នូវការញុះញង់ ដោយគ្មានការទទួលខុសត្រូវ និងមិនក្រែងរអែងលើការបំពានច្បាប់ សំដៅបង្កើតស្មារតីជាតិនិយមជ្រុល ធ្វើឱ្យមានការបែកបាក់ជាតិ និងបង្កើតការភាន់ច្រឡំនៅក្នុងចំណោមសាធារណមតិជាតិ និងអន្តរជាតិ ដើម្បីកេងចំណេញខាងនយោបាយ ដោយមជ្ឈដ្ឋានមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលជាប្រការអាចបង្កើតគ្រោះមហន្តរាយដ៏ធំធេងសម្រាប់ជាតិកម្ពុជាទាំងមូល ព្រមទាំងសម្រាប់សុខសន្តិភាពរវាងកម្ពុជាជាមួយប្រទេសជិតខាងក្នុងតំបន់ និង

ទី៣ - បញ្ជាក់ជាថ្មីម្តងហើយម្តងទៀត អំពីការប្តេជ្ញាចិត្តដ៏មោះមុតឥតងាករេរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តន៍គោលនយោបាយរបស់ខ្លួនសំដៅកសាងខ្សែបន្ទាត់ព្រំដែនមួយច្បាស់លាស់ ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ជាមួយនឹងប្រទេសជិតខាង។

ក្នុងស្មារតី និងគោលបំណងខាងលើ ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះផ្តល់ការបំភ្លឺដោយផ្ទាល់ជូនដល់ជនរួមជាតិកម្ពុជាគ្រប់រូប បន្ថែមទៅលើការបំភ្លឺទាំងឡាយដែលធ្លាប់បានធ្វើកន្លងមកដោយផ្តោតទៅលើចំណុច សំខាន់ៗដូចខាងក្រោមៈ

## I- អំពីសាវតានៃផែនទីព្រំដែនបច្ចុប្បន្ន រវាងកម្ពុជា និងវៀតណាម

ផែនទីផ្លូវការដែលរាជរដ្ឋាភិបាលបាននិងកំពុងប្រើប្រាស់ ក្នុងការកំណត់ព្រំដែនជាមួយប្រទេសវៀតណាម គឺជាប្រភេទផែនទី Bonne ខ្នាត ១/១០០ ០០០ ដែលជាមរតកប្រវត្តិសាស្ត្រ ដែលអាណាព្យាបាលបារាំង

និងព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានបន្សល់ទុកឱ្យ ពោលគឺ ផែនទីកំណត់ព្រំដែន ដោយផ្អែកតាមគោលការណ៍ **"ខ្សែព្រំដែនមិនកែប្រែ"** ( Uti Possidetis ) នៅពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង ហើយដែលព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋនាពេលនោះ បានបញ្ជាក់ថា បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ និងបានស្នើសុំឱ្យប្រទេសមហាអំណាចទទួលស្គាល់នៅក្នុងឆ្នាំ ១៩៦៤។

ផែនទី Bonne ខ្នាត ១/១០០ ០០០ នេះ គឺជាមូលដ្ឋានសំខាន់តែមួយគត់ ដែលត្រូវបានរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា យកមកប្រើប្រាស់ជាបន្តបន្ទាប់នៅក្នុងការចុះកិច្ចព្រមព្រៀងនិងសន្ធិសញ្ញាចំនួន ៣ ដែលទាក់ទងនឹងព្រំដែនគោក ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម គឺៈ

**ទី១ - សន្ធិសញ្ញាស្តីពីគោលការណ៍ដើម្បីដោះស្រាយព្រំដែននិងកិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈព្រំដែន រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមចុះកាលបរិច្ឆេទដូចគ្នា ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៣** : ផ្អែកតាមសន្ធិសញ្ញា និងកិច្ចព្រមព្រៀងខាងលើនេះ ភាគីទាំងសងខាងបានចាត់ទុកថា **ព្រំដែនរដ្ឋរវាងកម្ពុជានិងវៀតណាម គឺជាព្រំដែនដែលមានរួចហើយ ដែលមានគូសលើផែនទីខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិនដាក់ឱ្យប្រើប្រាស់មុនឆ្នាំ ១៩៥៤ ឬនៅកាលបរិច្ឆេទ កៀកបំផុតទៅនឹងឆ្នាំ ១៩៥៤។** ការកំណត់យកផែនទីនេះ គឺស្របទៅនឹងគោលការណ៍ច្បាប់អន្តរជាតិស្តីពី **"ខ្សែព្រំដែនមិនកែប្រែ"** ហើយវាក៏ស្របទៅនឹងផែនទីផ្លូវការដែលរាជរដ្ឋាភិបាលកម្ពុជា សម័យសង្គមរាស្ត្រនិយម នាពេលនោះបានប្រើប្រាស់ ដើម្បីប្តឹងទៅអង្គការសហប្រជាជាតិ អំពីការរំលោភឈ្លានពានលើទឹកដីកម្ពុជាពី

សំណាក់បរទេស។

**ទី២ - សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៨៥** : សន្ធិសញ្ញានេះបានកំណត់យកគោលការណ៍ដូចក្នុងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ ១៩៨៣ ខាងលើ ដោយកំណត់យកផែនទី Bonne ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិនដាក់ឱ្យប្រើប្រាស់មុនឆ្នាំ ១៩៥៤ ឬនៅកាលបរិច្ឆេទកៀក បំផុតទៅនឹងឆ្នាំ ១៩៥៤ (ដែលមានចំនួន ២៦ ផ្ទាំង អមសន្ធិសញ្ញា) និងផែនទី UTM ខ្នាត ១/៥០ ០០០ ដែលគូសខ្សែព្រំដែនចេញពីផែនទី Bonne ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ធ្វើជាមូលដ្ឋានក្នុងការកំណត់ខ្សែព្រំដែនគោករវាងប្រទេសទាំងពីរ។ ការកំណត់យកផែនទីដោយសន្ធិសញ្ញានេះ គឺការបន្តអនុវត្ត ដោយឥតងាករេតាមគោលការណ៍ច្បាប់អន្តរជាតិស្តីពី "ខ្សែព្រំដែនមិនកែប្រែ" និងតាមបណ្តាផែនទីដែលត្រូវបានប្រកាន់យកដោយព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក្រោយពេលដែលកម្ពុជាបានទទួលឯករាជ្យពីបារាំង។

(សេចក្តីអធិប្បាយបន្ថែម)

*ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះ ដើម្បីបញ្ជាក់ជូនបន្តិចលើទិដ្ឋភាពខ្លះ មិនមែនជាការឆ្លើយតបសម្រាប់ពួកប្រឆាំងផ្តាច់មុខទេ ក៏ប៉ុន្តែ គឺជាការបំភ្លឺចំពោះជនរួមជាតិដែលជាអ្នកស្នេហាជាតិពិតប្រាកដហើយដែលមិនមានការចង់បាននូវភាពចំណេញខាងនយោបាយណាមួយ។ តើហេតុអ្វីបានជាចាំបាច់ត្រូវមានផែនទី UTM ខ្នាត ១/៥០ ០០០ អមជាមួយ? ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់អំពីចំណុចនេះបន្តិច ត្រង់ថា ផែន*

ទី Bonne ខ្នាត ១/១០០ ០០០ ជាផែនទីមួយដែលពិបាករកឃើញអំពីចំណុចគោលនៃការបោះបង្គោលព្រំដែន ដូច្នេះភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការផ្ទេរព្រំដែនពីផែនទី Bonne ខ្នាត ១/១០០ ០០០ ចុះទៅកាន់ផែនទី UTM ខ្នាត ១/៥០ ០០០ ហើយនៅពេលខាងមុខ នៅពេលដែលយើងជួលក្រុមហ៊ុន ដាណឺម៉ាកមួយ (ភាគីទាំងពីរបានជួលក្រុមហ៊ុនដាណឺម៉ាកមួយ) យើងអាចឈានទៅផ្ទេរផែនទីរហូតដល់ទៅខ្នាត ១/២៥ ០០០។ សម្រាប់តំបន់ខ្លះនៅក្នុងប្រទេស គឺយើងឈានទៅប្រើដល់ទៅខ្នាត ១/១០ ០០០។

ដូច្នេះ ត្រង់ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអានជូននូវប្រការ ៣ ទាក់ទងទៅនឹងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ ដើម្បីបញ្ជាក់ជូនជនរួមជាតិ ថាតើមានការប្រែប្រួលរវាងផែនទី UTM និងផែនទីBonneឬទេ។ ប្រការ ៣ នៃកិច្ចព្រមព្រៀងបំពេញបន្ថែម ឆ្នាំ២០០៥ នេះ បានបញ្ជាក់ច្បាស់ថា "ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារបច្ចេកទេសសម្រាប់សម្រួលដល់ដំណើរការការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក គូភាគីសន្យាទាំងពីរបានឯកភាពគ្នា ៖ ១. ក្រុមជំនាញបច្ចេកទេសនៃភាគីនីមួយៗ នឹងពិនិត្យ និងធ្វើការផ្ទៀងផ្ទាត់ជាឯកតោភាគី នៃការចម្លងឡើងវិញនៃខ្សែព្រំដែនពីផែនទី Bonne ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន អមសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ ១៩៨៥ មកលើផែនទី UTM ខ្នាត ១/៥០ ០០០ អមសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ១៩៨៥។ កថាខណ្ឌចុងក្រោយនៃចំណុចនេះ បាននិយាយថា ចំពោះបណ្តាតំបន់ដែលភាគីគូសន្យាទាំងពីរ

*មិនទាន់ឯកភាពគ្នាទៅលើលទ្ធផលនៃការប្រៀបធៀប ឬទៅលើដំណោះស្រាយបច្ចេកទេសខ្សែព្រំដែនក្នុងតំបន់ទាំងនោះ នឹងគ្មានប្រែប្រួលអ្វីឡើយ ដូចបានកំណត់ទៅលើផែនទី* Bonne *ខ្នាត ១/១០០ ០០០។*

*ចំណុចនេះគឺច្បាស់ណាស់ថា តំបន់មួយចំនួនដែលនៅមិនទាន់ដោះស្រាយបច្ចុប្បន្ន គឺជាការដែលយើងមិនទាន់ផ្ទេរផែនទីចេញពីផែនទី* Bonne *ទៅកាន់* UTM *បានច្បាស់លាស់ បានជាទីកន្លែងនោះមិនទាន់បានដោះស្រាយនៅឡើយ។ ឥឡូវនេះ ខាងមុខ ខ្ញុំព្រះករុណាខ្ញុំនឹងនិយាយមួយជំហានទៀត។ ថ្ងៃមុន ខ្ញុំព្រះករុណាខ្ញុំ បានជួបជាមួយនឹងបេសកជនពិសេសរបស់វៀតណាម ហើយបានលើកថា ប្រសិនបើភាគីទាំងពីរមិនឯកភាពគ្នាលើការផ្ទេរខ្សែផែនទី ពីផែនទី* Bonne *ទៅកាន់*UTM *ទេ យើងត្រូវសុំអ្នកបច្ចេកទេសបរទេស ឬជួលអ្នកបច្ចេកទេសបរទេសយកមក ដើម្បីផ្ទេរផែនទីនេះតែម្តង។ នេះ ដើម្បីជានាទូវភាពត្រឹមត្រូវច្បាស់លាស់ ទៅលើបញ្ហាទាក់ទិនជាមួយផែនទីដែលត្រូវផ្ទេរ ពីផែនទី* Bonne *ខ្នាត ១/១០០ ០០០ ទៅកាន់ផែនទី* UTM *ខ្នាត ១/៥០ ០០០ ផង និងដើម្បីជានាភាពត្រឹមត្រូវទៅលើការបោះបង្គោលតាមខ្សែបន្ទាត់ព្រំដែនផង។ ដោយសារតែនិយាយទៅដល់ប្រការនេះខ្ញុំព្រះករុណាខ្ញុំក៏សូមបញ្ជាក់ថា នៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ក៏មាននិយាយទៅដល់បញ្ហាចំណុចទី៥ ដែលជាចំណុចចុងក្រោយនៃកិច្ចព្រមព្រៀងនេះ ដើម្បីបង្កលក្ខណៈងាយស្រួល គឺបាននិយាយថា រហូតដល់ពេលដែលការងារខណ្ឌសីមា និងបោះបង្គោលព្រំដែន មិនទាន់*

ត្រូវបានបញ្ចប់ទេនោះ ការគ្រប់គ្រងខ្សែព្រំដែន នឹងបន្តអនុវត្តតាមសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥ របស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ។ នៅក្នុងសេចក្តីប្រកាសនោះ ខ្ញុំព្រះករុណាខ្ញុំសូមអានសេចក្តីប្រកាសរបស់នាយករដ្ឋមន្ត្រីទាំងពីរ ដែលបាននិយាយច្បាស់នៅត្រង់ចំណុច "ភាគីទាំងពីរបញ្ជាក់សាជាថ្មីពីឆន្ទៈរបស់ខ្លួន ក្នុងការកសាងព្រំដែនរវាងប្រទេសទាំងពីរ ឱ្យក្លាយទៅជាព្រំដែនសន្តិភាព មិត្តភាព និងស្ថិរភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ និងភាពជាអ្នកជិតខាងល្អរវាងប្រទេសទាំងពីរ។

ដោយរង់ចាំដំណោះស្រាយលើបញ្ហាព្រំដែនដ៏សំខាន់នេះ ភាគីទាំងពីរឯកភាពរក្សាស្ថានភាពការគ្រប់គ្រងបច្ចុប្បន្ន ដោយមិនឱ្យមានការផ្លាស់ប្តូរ ឬរំកិលបង្គោលព្រំដែន និងអប់រំប្រជាជនដោយហាមប្រាមពួកគាត់មិនឱ្យធ្វើស្រែចំការ ឬតាំងទីលំនៅឆ្លងកាត់ព្រំដែន និងសហការគ្នារក្សាឱ្យបាននូវព្រំដែនសន្តិភាព និងសណ្តាប់ធ្នាប់"។ ក្នុងចំណុចនេះ គឺជាចំណុចដែលមានសារៈសំខាន់ សម្រាប់ការដោះស្រាយព្រំដែនរវាងយើងជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម។ យើងក៏ប្រើរូបមន្តដូចគ្នានេះ ជាមួយនឹងព្រំដែនជាមួយថៃ និងព្រំដែនជាមួយឡាវ អំពីការរក្សានូវស្ថានភាពដដែលនៃការគ្រប់គ្រងបច្ចុប្បន្ន នៅតំបន់ដែលមិនទាន់បានដោះស្រាយ។ ក្នុងចំណុចនេះដែរ ខ្ញុំព្រះករុណាខ្ញុំ ក៏គួរតែនិយាយ ពីព្រោះខ្ញុំព្រះករុណាខ្ញុំ ក៏នឹងបកស្រាយអំពីចំណុចដាក់ដាំ ដាក់ហ្វ៊ិត។ កិច្ចព្រមព្រៀងបំពេញបន្ថែមឆ្នាំ២០០៥ គឺមាននិយាយអំពីបញ្ហាទាក់ទិនអំពីចំណុចចុង

ក្រោយ អំពីកំណាត់ព្រំដែនតំបន់ជាប់នឹងឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី របស់កម្ពុជា និងឃុំក្វាងជិក ស្រុកដាក់រឡឹប ខេត្តដាក់ឡាក់(ដាក់នង) របស់វៀតណាម។ ភាគីគូសន្យាទាំងពីរ បានឯកភាពគ្នាបន្តការពិភាក្សា។ ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ នឹងបញ្ជាក់នៅខាងក្រោមទៀតដើម្បីបញ្ជាក់ឱ្យឃើញថា ការឈឺចាប់របស់ខ្ញុំព្រះករុណាខ្ញុំ ល្មមគ្រប់គ្រាន់ដើម្បីឱ្យខ្ញុំព្រះករុណាខ្ញុំ ធ្វើការបកស្រាយពន្យល់ឱ្យប្រជាពលរដ្ឋ ព្រះសង្ឃនិងប្រជាពលរដ្ឋយល់ឱ្យច្បាស់អំពីបញ្ហានេះ ថាហេតុអ្វី បានជាខ្ញុំព្រះករុណាខ្ញុំ ត្រូវតស៊ូលើបញ្ហានេះ នៅពេលដែលរដ្ឋាភិបាលជំនាន់មុន តាំងពីឆ្នាំ១៩៦៤ បានបោះបង់ចោលរួចស្រេច តាមរយៈការបញ្ជូនផែនទីទៅកាន់អង្គការសហប្រជាជាតិ។

[...] ខ្ញុំព្រះករុណាខ្ញុំ ចង់បានណាស់នូវអ្វីដែលជាផលប្រយោជន៍ជាតិ តាមភាពត្រឹមត្រូវដែលប្រវត្តិសាស្ត្របានបន្សល់ទុក ក៏ប៉ុន្តែពួកប្រឆាំងពួកអគតិ គេមានយោគយល់ចំពោះខ្ញុំព្រះករុណាខ្ញុំ ឬទេ ក្រៅតែពីការដាន់ពន្ទិចបន្ថែមនោះ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ថា មានអ្នកដែលបាននិយាយថា ផែនទីដែលរកឃើញនៅអាមេរិកគ្មានចុះហត្ថលេខាដោយវៀតណាម ឬដោយអ្នកណាទេ។ ច្បាស់ណាស់ ខ្ញុំព្រះករុណាខ្ញុំ ថ្ងៃនេះយកផែនទី ៤ ផ្ទាំង យកមក មានផែនទីអមសន្ធិសញ្ញា មានផែនទីគណបក្សសង្គ្រោះជាតិ មានផែនទីបារាំងដែលទើបនឹងប្រគល់ និងមានផែនទីដែលអង្គការសហប្រជាជាតិបានផ្តល់ ដើម្បីយកមកធ្វើជាការបង្ហាញ។ ទោះបីថា ខ្ញុំព្រះករុណាខ្ញុំ មានផែនទីពីអាមេរិករួចស្រេចទៅហើយ ដែលអ្នកខ្លះទើបតែបានរកឃើញក្នុងប៉ុន្មាន

ថ្ងៃមុននេះ ក៏ប៉ុន្តែខាងរាជរដ្ឋាភិបាលមានផែនទីនេះ តាំងពីជាង ១០ ឆ្នាំមុននោះៗ ហេតុអ្វីបានជាផែនទីនេះត្រូវមានចុះហត្ថលេខាដោយមនុស្ស ៤ នាក់? សូមបញ្ជាក់ថា ផែនទីអមសន្ធិសញ្ញា ចុះហត្ថលេខាអមដោយមនុស្ស ៤ នាក់គឺប្រធានក្រុមបច្ចេកទេសផែនទីរបស់កម្ពុជា ដោយលោក យាង យឿន, ប្រធានក្រុមបច្ចេកទេសផែនទីខាងវៀតណាម ដោយលោក វូ ង៉ឿម, ប្រធានគណៈប្រតិភូរដ្ឋាភិបាលក្នុងគណៈកម្មការចម្រុះ របស់កម្ពុជា ដោយឯកឧត្តម ឌិត មុន្ទី បច្ចុប្បន្នជាប្រធានតុលាការកំពូល, ប្រធានគណៈប្រតិភូខាងរដ្ឋាភិបាលវៀតណាមក្នុងគណៈកម្មការចម្រុះ ឈ្មោះ លីវ វ៉ាន់ឡឺយ។ ហេតុអ្វីបានជាយើងចាំបាច់ត្រូវមានហត្ថលេខានៅលើផែនទីយ៉ាងដូច្នេះ? ពីព្រោះមានបងប្អូនប្រជាពលរដ្ឋបានជ្រាបរួចហើយថា មេបក្សនយោបាយមួយបាននិយាយថា ផែនទីអាចទិញតាមផ្សារ ឬអាចទិញតាមបណ្ណាល័យបាន។ បើផែនទីរកកន្លែងណាក៏បានដែរ ផែនទីនោះ វាងាយណាស់នៅក្នុងការបន្ទំ។ សូម្បីតែបណ្ដាកុងត្រានីមួយៗ ឬឯកសារជាអនុក្រឹត្យ ឬព្រះរាជក្រឹត្យ ឬច្បាប់ ក៏សុទ្ធតែមានបោះត្រា/ប្រថាប់ត្រា ដោយមិនឱ្យមានការក្លែងបន្ទំនៅក្នុងទំព័រណាមួយទេ។ ដូច្នេះ ផែនទី ២៦ ផ្ទាំង បើសិនជាមិនមាននូវហត្ថលេខាទាំង ២៦ ផ្ទាំងទេ អ្នកដទៃអាចនឹងយកផែនទីមកដាក់ មិនថាភាគីកម្ពុជា ឬភាគីវៀតណាម នោះទេ។ នេះជាការភាន់ច្រឡំដ៏ធំ។ សូមបងប្អូនជនរួមជាតិ មើលតែខ្លួនឯងទៅថា សូម្បីតែក្រដាសត្រឹមតែ ៣ ទំព័រ ក៏ត្រូវការហត្ថលេខាទាំង ៣ ទំព័រ ដែរ ដើម្បីធានាសុក្រិតភាពលើផ្លូវច្បាប់។ ចុះទម្រាំដល់ទៅផែនទីរដ្ឋ វាត្រូវ

ច្បាស់ណាស់ ផែនទីរដ្ឋត្រូវការទាំងការចុះហត្ថលេខាពីសំណាក់រាជរដ្ឋាភិបាលពីសំណាក់ថ្នាក់ដឹកនាំរដ្ឋាភិបាល។ ផែនទីអម ត្រូវចុះហត្ថលេខាដោយអ្នកបច្ចេកទេស ហើយត្រូវសុំការអនុម័ត ឱ្យសច្ចាប័នពីរដ្ឋសភា ពីនីតិបញ្ញត្តិ ហៅថា ពីអង្គនីតិបញ្ញត្តិ ដែលប្រទេសខ្លះមានត្រឹមតែរដ្ឋសភា ត្រូវសុំត្រឹមរដ្ឋសភា។ ប្រទេសខ្លះមានទាំងរដ្ឋសភាផង និងព្រឹទ្ធសភាផង ត្រូវសុំទាំងពីរ រួចហើយមានឡាយព្រះហស្តលេខារបស់ព្រះមហាក្សត្រ។ សូមយល់ដឹងថា សូម្បីតែការកាត់ភូមិមួយ ឬកាត់ឃុំមួយ កំណត់ព្រំប្រទល់ឃុំ ឬកំណត់ព្រំប្រទល់ភូមិត្រូវចេញសេចក្តីសម្រេចដោយអនុក្រឹត្យ។ ត្រូវបង្កើតស្រុក ព្រំប្រទល់ស្រុក ឃុំ ភូមិ ត្រូវកំណត់ដោយអនុក្រឹត្យ។ ព្រំប្រទល់ខេត្ត និងខេត្ត ត្រូវកំណត់ដោយព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ។ ព្រំប្រទល់រវាងរដ្ឋ និងរដ្ឋ ត្រូវឱ្យសច្ចាប័ន យល់ព្រមពីអង្គនីតិបញ្ញត្តិ និងឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។

ត្រង់ចំណុចនេះ យើងត្រូវយល់ឱ្យច្បាស់ ដោយសារតែផែនទីដែលមានចុះហត្ថលេខាបែបនេះហើយទើបជាផែនទីដែលមិនអាចក្លែងបន្លំបាន ទោះក្នុងកាលៈទេសៈមានសង្គ្រាមឬមានកលិយុគ យ៉ាងណាក៏ដោយ។ សូមបងប្អូនជនរួមជាតិយល់ថា សូម្បីតែក្រដាសប្រាក់ចាយ ១០០ក្តី, ២០០ ក្តី, ៥០ រៀល ក្តី, ក៏គង់មានចុះហត្ថលេខាដោយទេសាភិបាល និងបេឡា ត្រឹមត្រូវ បើមិនដូច្នោះ អ្នកដែលអាចបោះពុម្ពក្រដាសប្រាក់យកទៅក្លែងក្លាយតាមទីផ្សារ។ ដូច្នេះ ខ្ញុំព្រះករុណាខ្ញុំ មានការចាំបាច់ដើម្បីពន្យល់ ថាហេតុអ្វីទើបមានការចុះហត្ថលេខា? តើការចុះហត្ថ

*លេខានេះ វានាំទៅជាអាណានិគម ក្រោមអាណានិគមរបស់វៀតណាម ឬក៏ជាការស្មើភាព និងស្មើសិទ្ធិជាមួយនឹងវៀតណាម នាដំណាក់កាលនោះ។ បើសិនមានការចុះហត្ថលេខាដោយតែវៀតណាមម្នាក់ឯង នោះគឺច្បាស់ណាស់ថា កម្ពុជានឹងមិនអាចទទួលយកបានទេ ហើយបើសិនជាចុះហត្ថលេខាដោយកម្ពុជាតែឯង ក៏វៀតណាមមិនអាចទទួលយកបានដែរ ពីព្រោះយើងត្រូវធ្វើព្រំដែនជាមួយនឹងប្រទេសដទៃ។*

**ទី៣ - សន្ធិសញ្ញាបំពេញបន្ថែមរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥** : ផែនទីព្រំដែនដែលប្រើក្នុងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ នេះ គឺជាប្រភេទ **ផែនទី Bonne ខ្នាត ១/១០០ ០០០** ដដែលដូចក្នុងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ ១៩៨៣ និងសន្ធិសញ្ញាព្រំដែនរដ្ឋឆ្នាំ ១៩៨៥ ដែលបានរៀបរាប់ខាងលើ។ បន្ថែមលើនេះ តាមរយៈសន្ធិសញ្ញាបំពេញបន្ថែមនេះ កម្ពុជា និងវៀតណាម ក៏បានឯកភាពលើចំណុចសំខាន់ៗមួយចំនួនទៀតទាក់ទងនឹងផែនទី សំដៅបង្កើតឱ្យបាននូវផែនទីព្រំដែនមួយស្អាតរ និងអចិន្ត្រៃយ៍ ដែលខ្ញុំព្រះករុណាខ្ញុំធ្លាប់បានផ្ដល់ការបំភ្លឺលម្អិតរួចហើយនៅក្នុងបទអន្តរាគមន៍រយៈពេលជាង ៥ ម៉ោង ជូន រដ្ឋសភា កាលពីថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២ កន្លងទៅ។

(សេចក្ដីអធិប្បាយបន្ថែម)

*ហើយការបំភ្លឺនោះទៀតសោត គឺបានចាក់ផ្សាយតាមទូរទស្សន៍ និងក៏មានការបោះផ្សាយជាសៀវភៅនៃច្បាប់ដើមនេះរកបាននៅតាមបណ្ណាល័យ ហើយប្រសិនបើមានការចាំបាច់*

*យើងនឹងចាក់ផ្សាយបន្តទៀតនៅគ្រប់ស្ថានីយ៍ និងវិទ្យុ ដើម្បីការយល់ ប៉ុន្តែវាជាការលំបាកណាស់ នៅពេលដែលយើងផ្ដល់ឱ្យក្របីស្ដាប់ ហើយយើងពិបាកខ្លាំងណាស់ គ្មាននរណាងងឹតជាងមនុស្សដែលមានភ្នែកភ្លឺ ហើយធ្វើជាខ្វាក់ និងគ្មាននរណាដែលថ្លង់ជាងមនុស្សដែលមានត្រចៀកល្អ តែមិនព្រមស្ដាប់នោះទេ។*

ជារួម សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីព្រំដែនអមសន្ធិសញ្ញានេះ គឺពិតជាមានអត្ថប្រយោជន៍ជាប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជា ក្នុងការកសាងព្រំដែនអចិន្ត្រៃយ៍មួយជាមួយនឹងប្រទេសវៀតណាម។ សន្ធិសញ្ញានេះមិនត្រឹមតែបានបញ្ជាក់យ៉ាងច្បាស់លាស់សារជាថ្មី អំពីការជ្រើសរើសរបស់កម្ពុជានូវគោលការណ៍ច្បាប់អន្តរជាតិដែលហៅថា **"គោលការណ៍ខ្សែព្រំដែនមិនកែប្រែ"** (Uti Possidetis) នៅពេលកម្ពុជាទទួលបានឯករាជ្យ ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែនកម្ពុជាជាមួយប្រទេសជិតខាងប៉ុណ្ណោះទេ ប៉ុន្តែសន្ធិសញ្ញានេះថែមទាំងបានជួយជួសជុល កែលម្អនិងបំពេញបន្ថែម ទាំងខាងគោលការណ៍ច្បាប់ ទាំងខាងបច្ចេកទេសទៅលើចំណុចខ្វះខាតទាំងឡាយនៃសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥ ទៀតផង។ ដូចនេះ សន្ធិសញ្ញាបំពេញបន្ថែមនេះបានបន្តកិច្ចការដែលជាមរតកប្រវត្តិសាស្ត្រនៃរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ដើម្បីនាំទៅរកការបញ្ចប់ទាំងស្រុងនូវខ្សែព្រំដែនមួយច្បាស់លាស់ ទាំងលើផែនទី ទាំងលើដីជាក់ស្ដែង ដើម្បីធានាបាននូវបូរណភាពទឹកដីកម្ពុជា និងដើម្បីឱ្យប្រជាជនកម្ពុជាលែងមានការស្រពិចស្រពិល ស្គាល់ច្បាស់នូវព្រំដែនពិតប្រាកដរបស់ខ្លួន តាមរយៈបង្គោលព្រំដែនដែលស្ដែងឡើងនៅលើដីជាក់ស្ដែង ហើយងាយស្រួលក្នុងការចំណាំ ការគ្រប់គ្រង ការការពារ

និងការអភិវឌ្ឍន៍ នៅតំបន់តាមព្រំដែន ព្រមទាំងនាំមកជូនភាគីទាំងសង ខាងនូវទំនាក់ទំនងជាអ្នកជិតខាងកាន់តែល្អប្រសើរ សុខសន្តិភាព និង ភាពរីកចម្រើនរុងរឿង ទាំងខាងសង្គមកិច្ច សេដ្ឋកិច្ច ពាណិជ្ជកម្ម ការ វិនិយោគ និងការផ្លាស់ប្តូរទេសចរណ៍។

(សេចក្តីអធិប្បាយបន្ថែម)

*ចំណុចនេះវាសំខាន់ខ្លាំងណាស់ សម្រាប់ប្រទេសរបស់ យើង។ ព្រំដែននៅទិសខាងលិច រវាងកម្ពុជា និងថៃ បានប្រើ ប្រាស់តាមរយៈអនុស្សរណៈ នៃការយោគយល់គ្នាឆ្នាំ ២០០០ ដែលប្រើប្រាស់ផែនទីខ្នាត ១/២០០ ០០០ ដែលគណៈកម្មការ បារាំង-សៀម បានធ្វើ។ ជាមួយនឹងឡាវ យើងកំពុងដំណើរការ ទៅតាមកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ ដែលផ្អែកជាគោលនូវផែនទី ខ្នាត ១/១០០ ០០០។ ជាមួយវៀតណាម យើងកំពុងតែធ្វើនៅ លើអ្វីដែលខ្ញុំព្រះករុណាខ្ញុំ បានបញ្ជាក់នៅក្នុងសន្ធិសញ្ញាឆ្នាំ ១៩៨៣, ១៩៨៥ ហើយជាពិសេស គឺបន្តមកឆ្នាំ២០០៥ ដែល ខ្ញុំព្រះករុណាខ្ញុំបានបញ្ជាក់ជូនខាងលើអម្បាញ់មិញ ទាក់ទង ជាមួយនឹងការផ្ទេរខ្សែព្រំដែន ពីផែនទី* Bonne *ខ្នាត ១/១០០ ០០០ ទៅផែនទី* UTM *ខ្នាត ១/៥០ ០០០។*

*ក្នុងករណីផ្ទេរមិនបានត្រឹមត្រូវ និងមិនបានឯកភាពគ្នា នោះផែនទី* Bonne *នៅតែជាផែនទីផ្លូវការ ហើយក្នុងករណី ខាងមុខ គឺយើងនឹងពិភាក្សារកជំនាញការបរទេសមកតែម្តង ដើម្បីជួយផ្ទេរផែនទី ពីផែនទី* Bonne *ទៅកាន់ផែនទី* UTM។ *ក្រៅពីនោះ ការរក្សាស្ថានភាពដដែល និងការបន្តការចរចា នៅ តំបន់ដាក់ដាំ ដាក់ហ៊ូត ដែលខ្ញុំព្រះករុណាខ្ញុំនឹងធ្វើអត្ថាធិប្បាយ*

*នៅពេលខាងមុខ។*

## II- អំពីតម្លៃគតិយុត្តនៃផែនទីព្រំដែនរវាងកម្ពុជា និងវៀតណាម

យោងតាមសាវតាដែលបានគូសបញ្ជាក់ខាងលើ ផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងប្រើប្រាស់ជាផ្លូវការ ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម គឺមានលក្ខណៈសមស្របទាំងស្រុងទៅនឹងគតិនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាពោលគឺមាត្រា ២ ដែលចែងថាៈ **"បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបំពានបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០ ០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣ - ១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣ - ១៩៦៩"**។

លើសពីនេះទៀត តម្លៃគតិយុត្តិនៃផែនទីព្រំដែននេះត្រូវបានពង្រឹងយ៉ាងរឹងមាំឥតរង្គោះរង្គើ តាមរយៈ **"ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥"** ដែលច្បាប់នេះត្រូវបានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា ដែលជាតំណាងឱ្យឆន្ទៈនៃប្រជាជាតិខ្មែរ អនុម័តយល់ព្រម កាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញ អង្គលើកទី ១០ នីតិកាលទី ១។ ស្របតាមនីតិវិធីជាធរមាន ច្បាប់នេះត្រូវបានព្រះករុណាព្រះបាទសម្តេច - ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះ

**រាជាណាចក្រកម្ពុជា** ឡាយព្រះហស្តលេខាប្រកាស ឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/១១០៥/០៣៩ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ បន្ទាប់ពីទទួលបានសេចក្តីក្រាបបង្គំទូលថ្វាយរួមគ្នា ពីសំណាក់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងរូបខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការនេះគួសបញ្ជាក់ដោយមិនអាចប្រកែកបានថា សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ នេះ ត្រូវបានផ្តល់សច្ចាប័នដោយគោរពយ៉ាងត្រឹមត្រូវទៅនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ដូចនេះជាគោលការណ៍ច្បាប់ បន្ទាប់ពីការផ្តល់សច្ចាប័នត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់ជាតិរួចមក សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីព្រំដែនដែលអមសន្ធិសញ្ញានេះបានក្លាយជាឯកសារផ្លូវការតែមួយគត់ ដែលមានតម្លៃគតិយុត្តត្រឹមត្រូវតាមច្បាប់សម្រាប់ព្រះរាជាណាចក្រកម្ពុជាធ្វើជាមូលដ្ឋានក្នុងការចរចា និងកំណត់ព្រំដែនជាមួយប្រទេសវៀតណាម។

(សេចក្តីអធិប្បាយបន្ថែម)

*ខ្ញុំព្រះករុណាខ្ញុំ សូមបង្ហាញជូននូវទិដ្ឋភាពច្បាប់ ពាក់ព័ន្ធជាមួយនឹងកិច្ចព្រមព្រៀង ព្រមទាំងផែនទីនេះ។ នេះគឺជាព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ ទាក់ទងទៅនឹងសន្ធិសញ្ញាបំពេញបន្ថែម ដែលក្នុងនោះ ផែនទីដែលអមសន្ធិសញ្ញា គឺជាផែនទីស្របច្បាប់តែមួយគត់។ ការឡាយព្រះហស្តលេខារបស់ព្រះករុណាព្រះមហាក្សត្រ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ ហើយដែលពេលនោះ មានការឡាយព្រះហស្តលេខា និងហត្ថលេខា រហូត*

*ទៅដល់ ៤ រូប ឯណោះ ក្រៅពីប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៅមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រីម្នាក់ទៀតផង។ អញ្ចឹងទេ នេះជាទិដ្ឋភាពផ្លូវច្បាប់ដែលមិនអាចបំពានបាន។ ខ្ញុំព្រះករុណាខ្ញុំ នឹងបញ្ជាក់ជូនថា បើទិដ្ឋភាពផ្លូវច្បាប់រឹងមាំប៉ុណ្ណឹងហើយ ហេតុអ្វីត្រូវការផែនទីយកមកផ្ទៀងដើម្បីបញ្ជាក់ពីបញ្ហានេះទៀត មានផែនទីប៉ុណ្ណឹងហើយ ហេតុអ្វីមិនចាត់ការពួកនេះភ្លាម នៅពេលដែលគេធ្វើខុសច្បាប់។ តើរាជរដ្ឋាភិបាលមានភាពទន់ភ្លន់ និងចង់បង្ហាញនូវអ្វីដែលជាផលប្រយោជន៍ជាតិរបៀបណា? នោះហើយគឺជាការចង់បានរបស់រាជរដ្ឋាភិបាល ទៅលើបញ្ហាទាក់ទិននឹងការឯកភាពជាតិ ហើយឯកភាពដំបូង គឺចាប់ផ្តើមពីការប្រើប្រាស់ផែនទីនោះឯង។*

មួយវិញទៀត សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ គឺជាកិច្ចព្រមព្រៀងទ្វេភាគីដែលមានតម្លៃគតិយុត្ត ស្របតាមច្បាប់អន្តរជាតិ ជាពិសេស អនុសញ្ញាទីក្រុងវីយ៉េនស្តីពីនីតិសន្ធិសញ្ញាដែលព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម គឺជាភាគីហត្ថលេខី។ បន្ទាប់ពីសន្ធិសញ្ញានេះត្រូវបានផ្តល់សច្ចាប័ន ស្របតាមច្បាប់ផ្ទៃក្នុងនៃរដ្ឋជាភាគីរៀងៗខ្លួន និងបន្ទាប់ពីបានធ្វើការផ្លាស់ប្តូរលិខិតតូបករណ៍សច្ចាប័នរវាងគ្នារួចមក សន្ធិសញ្ញានេះបានចូលជាធរមាននិងមានអានុភាពអនុវត្តស្របតាមច្បាប់នៃប្រទេសនីមួយៗនឹងស្របតាមច្បាប់អន្តរជាតិសម្រាប់ភាគីទាំងពីរ។ **ដូចនេះ សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ និងផែនទីព្រំដែនអមសន្ធិសញ្ញានេះ ក៏ជាឯកសារផ្លូវការជាមូលដ្ឋានដែលមានតម្លៃគតិយុត្តស្របតាមច្បាប់អន្តរជាតិផងដែរ សម្រាប់ជាមូលដ្ឋានក្នុងការចរចា និងកំណត់**

## ព្រំដែនរដ្ឋរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។

(សេចក្តីអធិប្បាយបន្ថែម)

*ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់! យោងទៅលើទិដ្ឋភាពទាំងឡាយក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ នៅពេលដែលមានកិច្ចព្រមព្រៀង ដែលតម្រូវឱ្យមានការសុំសច្ចាប័នពីរដ្ឋសភា។ នៅកម្ពុជា មានកិច្ចព្រមព្រៀងខ្លះមិនតម្រូវឱ្យមានការសុំសច្ចាប័នពីរដ្ឋសភាទេ ក៏ប៉ុន្តែកិច្ចព្រមព្រៀងព្រំដែន ជាទូទៅ មិនថាប្រទេសកម្ពុជា ឬប្រទេសណាទេ តម្រូវឱ្យមានសច្ចាប័នពីនីតិបញ្ញត្តិ បើសិនជាប្រទេសណាមួយមិនឱ្យសច្ចាប័នគឺមានន័យថារាជរដ្ឋាភិបាល ឬរដ្ឋាភិបាលទៅចុះហត្ថលេខានោះ គឺអនុវត្តមិនបានទេ។ ឱ្យសច្ចាប័នរួចហើយ ភាគីទាំងពីរត្រូវប្តូរសារគ្នាទៅវិញទៅមក ដែលគេហៅថាលិខិតតូបករណ៍ ដើម្បីឱ្យក្លាយទៅជាផ្លូវច្បាប់ ហើយមានការឯកភាព។ ហេតុអ្វីបានជាចាំបាច់ត្រូវធ្វើយ៉ាងដូច្នេះ? កុំថាឡើយរវាងរដ្ឋ និងរដ្ឋ សូម្បីតែព្រំដីយើងជាមួយអ្នកជិតខាង ក៏ត្រូវការឯកភាពគ្នាថា តើត្រូវធ្វើរបងរបៀបណា? បើសិនជាខ្ញុំធ្វើរបងបំពានទៅលើដីអ្នកដទៃ ឬអ្នកដទៃធ្វើរបងបំពានមកលើដីខ្ញុំ គឺច្បាស់ជាមានជម្លោះរវាងគ្រួសារទាំងពីរដែលរស់នៅជិតខាងគ្នា។ កុំនិយាយឡើយរវាងរដ្ឋ និងរដ្ឋដែលសងខាងសុទ្ធតែមានកងទ័ព សុទ្ធតែមានកម្លាំងប្រដាប់អាវុធ។ ទាំងយើងជាមួយវៀតណាម ទាំងយើងជាមួយឡាវ ទាំងយើងជាមួយថៃ ទាំងថៃជាមួយឡាវ ទាំងថៃជាមួយមីយ៉ាន់ម៉ា ទាំងថៃជាមួយនិងកម្ពុជា វៀតណាមជាមួយកម្ពុជា វៀតណាមជាមួយឡាវ វៀតណាមជាមួយចិន គឺសុទ្ធតែត្រូវមានការឯកភាព*

*គ្នាទាំងអស់។*

*ដូច្នេះ ព្រំដែនរបស់យើង ផែនទីដែលយើងប្រើប្រាស់មិនមែនជាផែនទីដែលយើងដាក់ចេញជាឯកតោភាគី ហើយតម្រូវឱ្យភាគីម្ខាងទៀតត្រូវតែទទួលយកនោះទេ។ ហើយយើងក៏មិនអាចទទួលយកនូវផែនទីដែលប្រទេសដទៃនៅជាប់ជិតខាងយើង តម្រូវឱ្យយើងទទួលយកនោះ ក៏ទេដែរ។ ដូច្នេះបានជាយើងជាមួយថៃ យើងជាមួយឡាវ យើងជាមួយវៀតណាម ចាំបាច់ត្រូវតែមានការឯកភាពគ្នាទៅលើការប្រើប្រាស់ផែនទី។ ដូច្នេះផែនទីរបស់យើងនេះ តម្រូវក្នុងទិដ្ឋភាពច្បាប់ លើបញ្ហាច្បាប់ផ្ទៃក្នុងខ្លួនឯងផង បានបំពេញគ្រប់គ្រាន់តាមផ្លូវច្បាប់នៅក្នុងផ្ទៃក្នុងខ្លួនឯងផង និងទៅតាមក្របខ័ណ្ឌច្បាប់អន្តរជាតិផងដែរ។*

ផ្អែកលើគ្រប់ទិដ្ឋភាពទាំងអស់ខាងលើនេះ ផែនទីព្រំដែនដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែនជាមួយនឹងប្រទេសវៀតណាមនេះ គឺជាផែនទីផ្លូវការតែមួយគត់ដែលមានតម្លៃ **គតិយុត្តពេញលេញ ទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជានិងដោយច្បាប់ អន្តរជាតិ ដើម្បីប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងការកំណត់ព្រំដែនរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម។**

បន្ថែមពីលើនេះទៀត នាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដែលជាថ្ងៃឡាយព្រហស្តលេខាលើព្រះរាជក្រម ប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ក៏បានចេញព្រះរាជសារ

ជូនជនរួមជាតិខ្មែរទាំងមូល ដែលមានខ្លឹមសារគួសបញ្ជាក់បន្ថែមទៀតថា គ្រប់ស្ថាប័នជាតិកំពូលរបស់ព្រះរាជាណាចក្រកម្ពុជា រួមមាន រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល ដែលជាតំណាងឱ្យឆន្ទៈនៃប្រជាជាតិខ្មែរទាំងមូលស្របតាមគោលការណ៍នៅក្នុងសង្គមប្រជាធិបតេយ្យ និងជាស្ថាប័នដែលទទួលខុសត្រូវចំពោះជោគវាសនារបស់ប្រទេសជាតិ បានពិនិត្យឃើញយ៉ាងច្បាស់ និងបានធានាអះអាងថា ផែនទីព្រំដែនកម្ពុជា និងវៀតណាមអមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ គឺជាផែនទីដែលមានភាពត្រឹមត្រូវ និងមិនធ្វើឱ្យបាត់បង់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

(សេចក្ដីអធិប្បាយបន្ថែម)

*ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមបង្ហាញប្រគេនចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិ! នេះជាព្រះរាជសាររបស់ព្រះមហាក្សត្រ ដែលព្រះអង្គបានផ្ញើជូនព្រះសង្ឃ និងបងប្អូនជនរួមជាតិ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ គឺនៅថ្ងៃដែលព្រះអង្គបានឡាយព្រះហស្ថលេខាលើព្រះរាជក្រម ដាក់ឱ្យប្រើប្រាស់ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែម ដែលក្នុងនោះមានអមដោយផែនទីនោះផង។ នៅក្នុងចំណុចនេះ ក្រៅពីការអះអាងពីសំណាក់រាជរដ្ឋាភិបាល ពីសំណាក់រដ្ឋសភា ពីសំណាក់ព្រឹទ្ធសភា ព្រះករុណាជាអង្គម្ចាស់ព្រះអង្គ ក៏បានពិគ្រោះយោបល់ជាមួយនឹងព្រះរាជវង្សានុវង្ស ដែលមានសម្ដេច ស៊ីសុវត្ថិ ជីវន្តមុនីរក្ស ដែលពេលនោះជាអនុប្រធានទីមួយនៃព្រឹទ្ធសភា សម្ដេចនរោត្តម សេរីវុឌ្ឍ ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសម្ដេចព្រះមហិសរានរោត្តម ចក្រពង្ស ដែលពេលនោះជាទីប្រឹក្សារាជរដ្ឋាភិបាល*

*ក៏បានថ្វាយនូវព្រះរាជយោបល់ថា ជាការទទួលខុសត្រូវរបស់អង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ។ ដូច្នេះ នេះជាការយកព្រះទ័យទុកដាក់។ បញ្ហានេះ គឺជាបញ្ហា ក្រៅពីនៅពេលដែលព្រមគ្នាឡាយព្រះហស្ថលេខាលើព្រះរាជក្រមដាក់ឱ្យប្រើប្រាស់នូវច្បាប់នេះ ព្រះអង្គក៏បានប្រទានព្រះរាជសារថ្វាយប្រគេនចំពោះព្រះសង្ឃ និងជូនចំពោះប្រជាពលរដ្ឋគ្រប់រូបរួចមកហើយដែរ ហើយដែលកន្លងទៅ វិទ្យុ និងទូរទស្សន៍ ក៏បានផ្សាយជាហូរហែផងដែរ ហើយសង្ឃឹមថាបណ្តាទូរទស្សន៍នានា នឹងបន្តចាក់ផ្សាយនូវព្រះរាជសាររបស់ព្រះករុណាព្រះមហាក្សត្របច្ចុប្បន្ន ក៏ដូចជាព្រះរាជសាររបស់ព្រះករុណាអតីតព្រះមហាក្សត្រ សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ផ្ញើជូន ឯកឧត្តម ផាម វ៉ាន់ដុង នៅឆ្នាំ១៩៩៩ ស្តីអំពីបញ្ហាព្រំដែនទឹក គឺដោយសុំយកលីងប្រេវីយ៉េ និងព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់នេះផងដែរ ដើម្បីចាក់ផ្សាយជូនជនរួមជាតិ ដើម្បីចៀសវាងនូវការធ្វើអត្ថាធិប្បាយ និងការញុះញង់បង្កហេតុ ពីសំណាក់ពួកមិនទទួលខុសត្រូវ ហើយដែលព្យាយាមធ្វើឱ្យសភាពការណ៍មានការអាប់អួរ ឬបង្កើតជាចលាចលឡើង។*

## III- **អំពីភាពត្រឹមត្រូវនៃផែនទីព្រំដែនកម្ពុជា និងវៀតណាម**

ផ្អែកលើសាវតានិងគតិច្បាប់ដូចបានរំលេចខាងលើនេះ ផែនទីព្រំដែនអមសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ ២០០៥ គឺជាផែនទីផ្លូវការតែមួយគត់ ដែលមានតម្លៃគតិយុត្តពេញលេញ ស្របតាមច្បាប់ជាតិ និងច្បាប់អន្តរ

ជាតិ សម្រាប់ការចរចានិងកំណត់ព្រំដែនរដ្ឋរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម។ ដូចនេះ តាមផ្លូវច្បាប់ វាពិតជាមិនមានការចាំបាច់ណាមួយដែលតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការស្វះស្វែងរកកិច្ចសហការស្នើសុំខ្ចីផែនទីដើម្បីផ្ទៀងផ្ទាត់ជាមួយផែនទីផ្លូវការ និងស្របច្បាប់ ដែលរាជរដ្ឋាភិបាលបាន និងកំពុងប្រើប្រាស់ ក្នុងការចរចាកំណត់ព្រំដែន និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាមនោះឡើយ។

(សេចក្តីអធិប្បាយបន្ថែម)

*នេះជាចំណុចដែល ខ្ញុំព្រះករុណាខ្ញុំ បានលើកឡើងពីខាងលើអម្បាញ់មិញ ថាបើមានផែនទីផ្លូវច្បាប់អញ្ចឹងហើយ ម៉េចបានចាំបាច់ទៅរកសុំខ្ចីគេ? ហើយចំណុចនេះ ចម្លើយនៅទីនេះនឹងមានផ្នែកខាងក្រោមដែល ខ្ញុំព្រះករុណាខ្ញុំ ក៏បានប្រាប់ទៅឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិថា សុំឯកឧត្តមកុំបន្ទោសខ្ញុំ ដែលខ្ញុំបានរកវិធីឱ្យសត្វមានពិសចេញពីរូង ព្រោះផែនទីរបស់ឯកឧត្តម វាសាហាវជាងសត្វអសិរពិសទៅទៀត ព្រោះមិនត្រឹមតែបោកប្រាស់ប្រជាពលរដ្ឋទេ ដោយសារផែនទីនោះហើយ បានធ្វើឱ្យសហការីរបស់គាត់ជាប់គុកមកដល់ពេលនេះមិនទាន់ចេញបាន ហើយអាចនឹងមានជាប់គុកជាបន្តបន្ទាប់ទៀត។ ការជាប់គុកនេះ គឺវាអាស្រ័យទៅលើតុលាការទេ តែឥឡូវនេះកំពុងតែជាប់ឃុំ។*

ទោះបីជាយ៉ាងនេះក្តី គណបក្សប្រឆាំង តំណាងដោយអ្នកនយោបាយមួយចំនួនរបស់ខ្លួននៅតែបន្ត ធ្វើជាមិនយល់អំពីតម្លៃគតិយុត្ត និងអត្ថប្រយោជន៍នៃសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ និងផែនទីព្រំដែនអមសន្ធិសញ្ញានេះ ហើយបែរជាធ្វើការចោទប្រកាន់មួលបង្កាច់យ៉ាងងងើល

ដោយមិនញញើតបន្តិចណាសោះ ចំពោះច្បាប់ជាធរមាន និងដោយប្រមាថមាក់ងាយឥតកោតក្រែងទៅលើស្ថាប័នកំពូលទាំងឡាយរបស់ជាតិ រួមទាំងស្ថាប័នព្រះមហាក្សត្រផងថា ផែនទីព្រំដែនផ្លូវការ និងស្របច្បាប់នេះ គឺជាផែនទីក្លែងក្លាយ ឬជាផែនទី មិនត្រឹមត្រូវ ឬជា **"ផែនទីចោរ"** ថែមទៀតផង។

(សេចក្តីអធិប្បាយបន្ថែម)

*ឥឡូវនៅទីនេះ តើទាំង ៤ តួអង្គនេះ ជាចោរ ឬយ៉ាងណា? នេះជាការប្រមាថ ដែលមិនត្រូវលើកលែង។ ព្រះមហាក្សត្រព្រះនាម នរោត្តម សីហមុនី, ប្រធានព្រឹទ្ធសភា ពិតមែនតែគាត់មរណកាលទៅហើយ តែគាត់នាម សម្តេច ជា ស៊ីម, ប្រធានរដ្ឋសភា ព្រះនាម នរោត្តម រណឫទ្ធិ, នាយករដ្ឋមន្ត្រី គឺខ្ញុំព្រះករុណាខ្ញុំ ហ៊ុន សែន តើនេះ អ្នកដែលប្រមាថចំពោះផែនទី ថាជាផែនទីចោរ ផែនទីមិនត្រឹមត្រូវ ផែនទីក្លែងក្លាយ តើមានបានគិតទៅដល់ស្ថាប័នកំពូលរបស់ជាតិ[...] តើការបំពានបែបនេះ ត្រូវទទួលទោសបែបណា? ស្នើឱ្យអង្គអ្នកច្បាប់ និងផ្នែកវិស័យតុលាការសិក្សាឱ្យបានច្បាស់លាស់ ដើម្បីចាត់វិធានការចំពោះជនទាំងឡាយណាដែលហ៊ានប្រមាថទៅលើផែនទី ដែលកំពុងប្រើប្រាស់ជាផ្លូវការនៅពេលនេះ។*

1. ដូចនេះ ដើម្បីធានាតម្លាភាពសម្រាប់ប្រជាជាតិកម្ពុជាទាំងមូល ក៏ដូចជាដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត អំពីភាពហ្មត់ចត់ ភាពត្រឹមត្រូវពិតប្រាកដ និងការទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការរៀបចំ និងការអនុវត្តន៍ការងាររបស់ខ្លួន ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេស

ជិតខាង រាជរដ្ឋាភិបាលកម្ពុជាបានស្វះស្វែងរកកិច្ចសហការ ស្នើសុំខ្ចីផែនទីដើមដែលមានការពាក់ព័ន្ធ ពីអង្គការសហប្រជាជាតិ និងពីប្រទេសមហាអំណាចចំនួន ៣ គឺ **សាធារណរដ្ឋបារាំង សហរដ្ឋអាមេរិក** និងចក្រភពអង់គ្លេស ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងផែនទីផ្លូវការ និងស្របច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងប្រើប្រាស់ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនជាមួយវៀតណាម។ ដូចបានគូសបញ្ជាក់ពីខាងដើម ការស្នើសុំខ្ចីផែនទីនេះ ក៏ធ្វើឡើងក្នុងគោលបំណង ដើម្បីបញ្ចៀស និងបញ្ចប់នូវការញុះញង់ដោយគ្មានការទទួលខុសត្រូវ និងដោយមិនខ្លាចញញើតច្បាប់រដ្ឋ សំដៅបង្កើតស្មារតីជាតិនិយមជ្រុល ធ្វើឱ្យមានការបែកបាក់ជាតិ និងបង្កើតឱ្យមានការភាន់ច្រឡំនៅក្នុងចំណោមសាធារណមតិជាតិ និងអន្តរជាតិ ដើម្បីកេងចំណេញនយោបាយដោយមជ្ឈដ្ឋានមួយចំនួននៅក្នុង ប្រទេសកម្ពុជាដែលជាប្រការអាចបង្កើតគ្រោះមហន្តរាយដ៏ធំធេងសម្រាប់ជាតិកម្ពុជាទាំងមូល ព្រមទាំងសម្រាប់សុខសន្តិភាពជាមួយប្រទេសជិតខាង និងក៏ដើម្បីបញ្ជាក់អំពីការប្តេជ្ញាចិត្តឥតងាករេរបស់រាជរដ្ឋាភិបាលក្នុង ការអនុវត្តគោលនយោបាយរបស់ខ្លួន សំដៅកសាងខ្សែបន្ទាត់ព្រំដែនមួយច្បាស់លាស់ត្រឹមត្រូវប្រកបដោយ សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ជាមួយប្រទេសជិតខាង។

(សេចក្តីអធិប្បាយបន្ថែម)

*អ្វីដែលរាជរដ្ឋាភិបាលចង់បាន គឺតម្លាភាពជាមួយប្រជាជាតិកម្ពុជាទាំងមូល ក៏ប៉ុន្តែ ខ្ញុំព្រះករុណាខ្ញុំ ក៏ចង់ឱ្យសត្វមានពិសចេញពីរូង ដែលវាសាហាវជាងសត្វអសិរពិស ព្រោះគេគ្រាន់តែបង្ហោះតាមហ្វេសប៊ុក ហើយគេបង្កើតនូវការញុះញង់ បោកបញ្ឆោតប្រជាពលរដ្ឋហើយ តើគេគួរទទួលខុសត្រូវចំពោះមុខ*

*ច្បាប់បែបណា ប្រសិនបើមានយថាហេតុអាក្រក់កើតឡើង? ដូចជាការកាប់សម្លាប់គ្នានៅក្នុងផ្ទៃក្នុងជាតិ ឬការប៉ះទង្គិចតាមទល់ដែន តាមរយៈការញុះញង់របស់មេដឹកនាំ យ៉ាងហោចណាស់គេក៏ត្រូវទទួលខុសត្រូវខាងសីលធម៌ផងដែរ នៅពេលដែលគេធ្វើការញុះញង់ បំបែកបំបាក់ជាតិ។ [...]*

នៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១៥ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ បានធ្វើលិខិតមួយច្បាប់ជូនទៅឯកឧត្តម Ban Ki-moon អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសុំខ្ចីផែនទីដើមទាំងអស់ដែលតម្កល់នៅអង្គការសហប្រជាជាតិ។នៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១៥ ឯកឧត្តម Ban Ki-moon បានធ្វើលិខិតឆ្លើយតបមកវិញ ដោយបញ្ជាក់ថា ពុំអាចរកឃើញផែនទី Bonne ខ្នាត ១/១០០ ០០០ ដែលរាជរដ្ឋាភិបាលសម្តេចព្រះ នរោត្តម សីហនុ បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៦៤ នោះទេ ប៉ុន្តែបានរកឃើញផែនទីចំនួន ១៨ ផ្ទាំង តម្កល់នៅបណ្ណាល័យ **ដាក់ហាំម៉ាស្ហ៊ុល** (Dag Hammar-skjöld) របស់អង្គការសហប្រជាជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជា សម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋបាន ប្រើប្រាស់ផែនទីនោះប្តឹងទៅអង្គការសហប្រជាជាតិ អំពីការរំលោភឈ្លានពានលើទឹកដីកម្ពុជាពីសំណាក់បរទេស។ អង្គការសហប្រជាជាតិបានអនុញ្ញាតឱ្យកម្ពុជាខ្ចីផែនទីទាំង ១៨ ផ្ទាំងនោះ ជាការយោគយល់ពិសេស។

(សេចក្តីអធិប្បាយបន្ថែម)

*ខ្ញុំព្រះករុណាខ្ញុំ សូមបំភ្លឺចំណុចនេះបន្តិច ៖ អង្គការសហប្រជាជាតិ តាមរយៈលិខិតអគ្គលេខាធិការ បាន គីមូន គ្រាន់តែ*

បានបញ្ជាក់ប្រាប់មកខ្ញុំព្រះករុណាខ្ញុំថា ផែនទីនេះរកមិនឃើញ។ ប៉ុន្តែមិនបានបញ្ជាក់ប្រាប់ថា បានយកទៅតម្កល់ ឬមិនបានយកទៅតម្កល់ នោះទេ។ ដូច្នេះ ក្នុងឋានៈជាក្មេងជំនាន់ក្រោយ ខ្ញុំព្រះករុណាខ្ញុំ មិនអាចដឹងបានថា តើពេលនោះ រាជរដ្ឋាភិបាលកម្ពុជា បានយកទៅតម្កល់មែនឬអត់? ឬយកទៅតម្កល់ តែអង្គការសហប្រជាជាតិធ្វើឱ្យបាត់? ឬមិនបានយកទៅតម្កល់?។ ដូច្នេះហើយ បានជាខ្ញុំព្រះករុណាខ្ញុំ នៅតែបន្តឱ្យស្វះស្វែងរកជាបន្តទៀត។ ខ្ញុំព្រះករុណាខ្ញុំ មិនយកការសន្និដ្ឋានណាមួយនៅពេលនេះថាតើនៅពេលនោះបានយកទៅតម្កល់ឬក៏អត់។ ឯ អគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏មិនបានបញ្ជាក់ក្នុងលិខិតរបស់ខ្លួនដែលផ្ញើមកខ្ញុំព្រះករុណាខ្ញុំ ថាមិនបានយកទៅតម្កល់ទេ គ្រាន់តែថារកមិនឃើញតែប៉ុណ្ណោះ។ ប៉ុន្តែគេបែរជារកឃើញនូវផែនទីដែលកម្ពុជាបានប្ដឹងទៅអង្គការសហប្រជាជាតិ ស្ដីអំពីការឈ្លានពានរបស់អាមេរិក និងវៀតណាមខាងត្បូង កាលពីពេលនោះទៅវិញ។ ផែនទីនេះ យើងអាចចាត់ទុកថា ជាផ្នែកមួយនៃព្រំដែនរបស់កម្ពុជាផងដែរ ព្រោះពេលដែលយើងបានដាក់ទៅ នូវទីតាំងទម្លាក់គ្រាប់បែកទាំងឡាយ មានន័យថា យើងបានកំណត់ថានេះជាដីខ្មែរ។ តាមរយៈនេះជាដីខ្មែរ នេះជាដីរបស់វៀតណាម តាមរយៈផែនទីដែលយើងបានដាក់ទៅ ទោះបីថាជាយើងមិនបានយកទៅតម្កល់ថាជាផែនទីព្រំដែន។ ប៉ុន្តែផែនទី ១៨ ផ្ទាំងនេះ ល្មមគ្រប់គ្រាន់ដើម្បីឱ្យយើងយល់ថា ពេលនោះព្រំដែនរបស់យើងគឺប៉ុណ្ណឹងអែង។ យើងក៏សុខចិត្តខ្ចីមក ហើយតាមលក្ខណៈ នេះជាការយោគយល់ ដែលយើងបានថ្លែងអំណរគុណ

*ចំពោះអគ្គលេខាធិការអង្គការសហប្រជាជាតិ។*

*ខ្ញុំព្រះករុណាខ្ញុំ សូមទម្លាយរឿងនេះដើម្បីជ្រាប។ នេះជាតំបន់ដែលមានការពាក់ព័ន្ធទៅក្នុងមាត្រាដែលពាក់ព័ន្ធជាមួយនឹងការបន្តការចរចាររវាងកម្ពុជា និងវៀតណាម នៅតំបន់ដាក់ដាំនិងដាក់ហ៊ូត តាមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥។ ចំណុចខ្សែព្រំដែននេះ សូមបញ្ជាក់ថា អគ្គទេសាភិបាលឥណ្ឌូចិន ឆ្នាំ ១៩១៨ បានកំណត់ឱ្យខ្សែព្រំដែនដើរមកតាមព្រែកដាក់ហ៊ូត ប៉ុន្តែបារាំងបានគូសផែនទីមកតាមព្រែកដាក់ដាំ ដែលខុសនឹងផ្ទៃដីប្រមាណជាង ៥០ គីឡូម៉ែត្រក្រឡា។ ខ្ញុំព្រះករុណាខ្ញុំ បានប្រឹងប្រែងណាស់ដើម្បីតស៊ូដោះស្រាយបញ្ហានេះ ស្នើឱ្យភាគីវៀតណាមទទួលយកនូវការគូសផែនទីឱ្យត្រឹមត្រូវទៅតាមការកំណត់នៃអគ្គទេសាភិបាលឥណ្ឌូចិនឆ្នាំ១៩១៨។ ពេលនោះ ខ្សែខៀវនេះ គឺជាខ្សែដែលខ្ញុំព្រះករុណាខ្ញុំ គូសព្រឹកមិញ ដើម្បីងាយពន្យល់ប្រជាពលរដ្ឋតែប៉ុណ្ណោះប៉ុន្តែខ្សែព្រំដែនដែលយើងបានប្រគល់ឱ្យអង្គការសហប្រជាជាតិ គឺខ្សែរត់តាមព្រែកដាក់ដាំហើយ ដែលតាំងពីពេលគូសផែនទីខុសមកដល់ពេលនេះ យើងមិនទាន់ស្វែងរកនូវឯកសារណាមួយ ដែលកម្ពុជាបានទាមទារឱ្យបារាំងគូសឡើងវិញ តវ៉ាឱ្យបារាំងគូសនោះទេ។ បារាំងបានគូសផែនទីខុសពីសេចក្ដីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន។ កម្ពុជាមិនបានតស៊ូទាមទារឱ្យបារាំងកែប្រែនូវការគូសខុសផែនទីនេះទេ ផ្ទុយទៅវិញ បានប្រើប្រាស់ផែនទីនេះ ហើយយកផែនទីនេះទៅប្ដឹងគេនៅអង្គការសហប្រជាជាតិ។ [...] អញ្ចឹងរឿងផ្ទៃដីនេះ ជារឿងដែលយើងកំពុងតស៊ូ សុំឱ្យវៀតណាម*

ទទួលយកនូវការកំណត់តាមការសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន។

ជាការគួរឱ្យចង់សើច ដែលមេដឹកនាំនយោបាយមួយរូបជាប្រធានបក្សនយោបាយ និយាយថា ផែនទីឆ្នាំ១៩១៤។ សុំប្រជាពលរដ្ឋយល់ឱ្យច្បាស់ បើធ្វើមេដឹកនាំរហូតដល់ល្ងង់ខ្លៅមិនដឹងថាអ្វីជាសេចក្ដីសម្រេច និងអ្វីជាផែនទីផង់នោះ តើសមស្របធ្វើជាមេដឹកនាំកម្ពុជាបានឬទេ? ប្រជាពលរដ្ឋត្រូវយល់ឱ្យច្បាស់ តើគួរបោះឆ្នោតជូនគាត់ដឹកនាំប្រទេសឬអត់? ប៉ុន្មានអាទិត្យមុននេះ គាត់ថា ត្រូវទាមទារឱ្យប្រើផែនទីឆ្នាំ១៩១៤។ ខ្ញុំសូមបញ្ជាក់ជូនបងប្អូនជនរួមជាតិ ក៏ដូចជាទៅកាន់សមាជិកសមាជិកាគណបក្សប្រឆាំង ឱ្យបានជ្រាបថា មេបក្សរបស់ខ្លួនល្ងង់ដល់ប៉ុណ្ណឹង តើអាចដឹកនាំជាតិបានឬទេ? សមស្របជាមេដឹកនាំរបស់ខ្លួនតទៅទៀតទេបើសូម្បីតែសេចក្ដីសម្រេច និងផែនទីគឺខ្លួនអត់ច្បាស់ផង។ សេចក្ដីសម្រេចគឺគេឱ្យដើរតាមព្រែកដាក់ហ៊្វិតរហូតដល់ប្រភពរបស់វា ប៉ុន្តែផែនទីគឺគូសតាមព្រែកដាក់ដាំ។ អញ្ចឹង អាផែនទីដែលគូសតាមដាក់ហ៊្វិត អត់មានផែនទីទេ មានតែសេចក្ដីសម្រេចប៉ុណ្ណោះ។ ឥឡូវ ដើម្បីជម្រះមន្ទិលតែម្ដង ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ជូនជនរួមជាតិ នេះជាការលះបង់តាំងពីឆ្នាំ១៩៦៤ ដែលពេលនោះ ឧត្តមសេនីយ៍ កែវ ផាត បានយកទៅប្ដឹងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៤ ហើយការយកទៅប្ដឹងគេ យកទៅផែនទីយ៉ាងដូច្នេះ។ មិនបានស្នើសុំបារាំងឱ្យកែផែនទីទេ មិនបានទាមទារឱ្យខ្សែផែនទីដើរស្របជាមួយសេចក្ដីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិនទេ ប៉ុន្តែបែរជាយកផែនទី

*ទៅប្តឹងគេនៅអង្គការសហប្រជាជាតិ ដែលជាផ្នែកមួយនៃព្រំដែនរបស់កម្ពុជា។*

*ខ្ញុំព្រះករុណាខ្ញុំ ទ្រាំឈឺចាប់លើបញ្ហានេះអស់រយៈកាលរហូតមកដល់ពេលនេះ បើគិតពីឆ្នាំ២០០៥ ហើយមុននឹងទៅទៀត គឺយូរណាស់មកហើយ [...] នៅពេលខ្ញុំព្រះករុណាខ្ញុំចង់ការពារទឹកដី តើមាននរណាមកការពារខ្ញុំព្រះករុណាខ្ញុំ ក្រៅតែពីការវាយប្រហារ ដាន់ពន្ទិចបន្ថែម ដើម្បីយកការឈ្នះឆ្នោតតែប៉ុណ្ណោះ តើខ្ញុំព្រះករុណាខ្ញុំខុសអ្វីទៅ ដែលគ្រាន់តែធ្វើការតស៊ូដើម្បីផលប្រយោជន៍ជាតិ ឱ្យមានការចរចាជាមួយវៀតណាម ដើម្បីទាញយកខ្សែផែនទីដែលគូសទៅតាមព្រែកដាក់ដាំ ឱ្យមកដើរតាមព្រែកដាក់ហ្វិត ស្របតាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិនតើខ្ញុំព្រះករុណាខ្ញុំខុសឬទេ? តើនេះជាស្មារតីក្បត់ជាតិ ឬក៏ជាស្មារតីស្នេហាជាតិ?*

*ឥឡូវ សូមមើលផែនទីរបស់គណបក្សសង្គ្រោះជាតិម្តងដែលចាត់ទុកខ្លួនឯងថា ជាផែនទីត្រឹមត្រូវ។ គណបក្សសង្គ្រោះជាតិនៅជំពាក់ផែនទីចំនួនពីរផ្ទាំង មានមួយផ្ទាំងនោះ គាត់យកផែនទីឥណ្ឌូចិនទាំងមូល(កម្ពុជា វៀតណាម ឡាវ) គាត់យកមកដាក់បង្ហោះ ហើយមានមួយផ្ទាំងទៀត គឺដីវៀតណាមទាំងអស់តែម្តង គឺថានៅ បា មី ធួត (Ban Me Thuot) ក្នុងខេត្តដាឡាក់របស់វៀតណាម។ គាត់នៅជំពាក់ពីរផ្ទាំងទៀត។ ប៉ុន្តែឥឡូវសូមមើល ខ្ញុំព្រះករុណាខ្ញុំនឹកស្មានថា ផែនទីរបស់សង្គ្រោះជាតិអាចមានភាពប្រសើរទៅលើចំណុចដែលគាត់អាចរកឃើញនូវភាពខ្លាំងខ្លះដែលអាចផ្តល់នូវទឡ្ហីករណ៍ ឱ្យរាជរដ្ឋាភិបាលយកទៅ*

ចរចាជាមួយវៀតណាម។ មិននឹកស្មានថាផែនទីនេះ គឺគ្រាន់តែជាផែនទីបោកប្រាស់ ហើយសាហាវជាងសត្វអសិរពិស។ ឥឡូវចំណុចដាក់ដាំ ដាក់ហ៊ូត គឺដូចគ្នាតែម្ដង។ នេះគឺព្រែកដាក់ដាំដដែល, នេះគឺ ដាក់ហ៊ូត ដែលខ្ញុំព្រះករុណាខ្ញុំទើបនឹងគូសព្រឹកមិញ។ អញ្ចឹងទេ តើផែនទីសង្គ្រោះជាតិ មានអ្វីប្រសើរជាងផែនទីរាជរដ្ឋាភិបាល បើវាដូចគ្នាជាមួយផែនទីរាជរដ្ឋាភិបាល ហើយអន់ជាងផែនទីរាជរដ្ឋាភិបាលទៅទៀត។ រាជរដ្ឋាភិបាលកំពុងតែទាមទារឱ្យវៀតណាមគូសបន្ទាត់មកតាមព្រែកដាក់ហ៊ូត តាមសេចក្ដីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន តើនេះឬជាទង្វើស្នេហាជាតិរបស់សង្គ្រោះជាតិរបស់មេដឹកនាំតែម្ដង ហើយចោទគេថាប្រើផែនទីក្លែងក្លាយ ក្នុងពេលដែលគេកំពុងព្យាយាមចរចាដើម្បីធ្វើម៉េចឱ្យស្របទៅនឹងសេចក្ដីសម្រេច របស់អគ្គទេសាភិបាលឥណ្ឌូចិន។ អ្នកណាស្នេហាជាតិ អ្នកណាក្បត់ជាតិ។ យើងមិនចង់និយាយនរណាក្បត់ជាតិ ប៉ុន្តែគេប្រើភាសាមកលើយើងអាក្រក់ណាស់ សាហាវណាស់ ពិសពុលណាស់។ ឥឡូវបានចេញមកកណ្ដាលវាលហើយ តំបន់ដាក់ដាំ ដាក់ហ៊ូត គឺគ្មានអ្វីខុសគ្នាជាមួយនឹងផែនទីដែលយកទៅអង្គការសហប្រជាជាតិទេ។ បន្ថែមលើនោះ ផែនទីបារាំងបញ្ជូនមក គឺដដែល ដូចគ្នាទាំងអស់។ អញ្ចឹង តើខ្ញុំព្រះករុណាខ្ញុំ តស៊ូនេះ ឬមកពីខ្ញុំព្រះករុណាខ្ញុំមិនព្រមតស៊ូ មិនព្រមលះបង់តំបន់ដាក់ដាំ ដាក់ហ៊ូតទើបសង្គ្រោះជាតិចោទខ្ញុំព្រះករុណាខ្ញុំ ថាប្រើផែនទីក្លែងក្លាយ។ សួរបែបនេះទៅវិញ មេដឹកនាំរបស់គេ គប្បីឆ្លើយឱ្យមានការគោរព និងមានសីលធម៌ បើផែនទីរបស់អ្នកឯងវាដូចបេះបិទជាមួយ

ផែនទីរបស់រាជរដ្ឋាភិបាល បន្ថែមលើនោះ អ្នកឯងជំពាក់ពីរផ្ទាំង ទៅទៀត។ ក្នុងពេលដែល ខ្ញុំព្រះករុណាខ្ញុំ សរសេរសំបុត្រឱ្យ ប្រធានាធិបតីបារាំង គេបង្ហោះថា ទិញត្រឹមតែ ១៦៨ ដុល្លារ។ សូម អ្នកនាំពាក្យនិយាយឱ្យច្បាស់ អាមួយបង់ថ្លៃ service, អាមួយ ទិញ។ នៅក្នុងហ្វេសប៊ុក គេប្រើភាសាទិញ។ ជាវបានតើអាហ្នឹង! ប៉ុន្តែអ្នកនាំពាក្យបែរជាមកធ្វើការកែតម្រូវ។ ខ្ញុំគិតថា ប្រជាពលរដ្ឋ និងអ្នកបច្ចេកទេសទាំងឡាយ ថតរក្សាទុកអស់ហើយ។ ក្រោយ ពេលបង្ហោះអាហ្នឹងរួចហើយ ទើបផ្ញើ SMS មកឱ្យខ្ញុំថា សុំកែ មាត្រា២ នៃរដ្ឋធម្មនុញ្ញ។ ការសុំកែមាត្រា២ នៃរដ្ឋធម្មនុញ្ញ មិន មែនបណ្ឌិតសុខ ទូច ឬអ្នកណាផ្សេងក្រៅពី ឯកឧត្តម សម រង្ស៊ី ទេ។ ខ្ញុំព្រះករុណាខ្ញុំចង់បង្ហាញថែមទៀត ដើម្បីបញ្ជាក់ឱ្យច្បាស់ អំពីចំណុចនេះ ព្រោះមាននៅក្នុងទូរស័ព្ទដៃនេះនៅឡើយទេ អំពីអ្វីដែល ដើម្បីយើងអានឱ្យស្ដាប់ទាំងអស់គ្នា ឱ្យយល់ទាំង អស់គ្នា។ ខ្លួនឯងជាអ្នកបង្កើតបញ្ហារួចហើយទម្លាក់ឱ្យអ្នកដទៃ ដោយខ្វះការទទួលខុសត្រូវ។ សូមអស់លោកចាប់យកទៅ នេះ ហើយជា SMS ទូរស័ព្ទរបស់ ឯកឧត្តម សម រង្ស៊ី មកចំពោះខ្ញុំ ហើយខ្ញុំអានឱ្យស្ដាប់អំពីចំណុចនេះ ដើម្បីជៀសវាងសមាជិក សមាជិកា ឬថ្នាក់ដឹកនាំ នៃគណបក្សប្រឆាំង ឬបក្សដទៃ យក ធ្វើជាល្បែង រហូតទៅដល់ជេរក្រុមស្រាវជ្រាវឯករាជ្យ។ នៅថ្ងៃ សុក្រ ១៧ កក្កដា ម៉ោង ៧:៤៩ នាទីព្រឹក ឯកឧត្តម សម រង្ស៊ី បាន ផ្ញើមកឱ្យខ្ញុំថា ជម្រាបសួរសម្ដេច ខ្ញុំសូមអបអរសាទរប្រសាសន៍ ថ្មីៗនេះរបស់សម្ដេច ទាក់ទងនឹងបញ្ហាព្រំដែន។ ដើម្បីបង្ហាញពី ឯកភាពជាតិកាន់តែរឹងមាំ ក្នុងបំណងការពារបូរណភាពទឹកដី

នៃប្រទេសកម្ពុជា ខ្ញុំសូមសម្តេចមេត្តាពិនិត្យលទ្ធភាព ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់មាត្រាទី២ ស្តីពីផែនទី ដែលយើងត្រូវបញ្ជាក់ឱ្យកាន់តែក្បោះក្បាយ ដោយមានការចូលរួមគាំទ្រពីគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិរួមគ្នា ដោយសេចក្តីគោរពរាប់អានពីខ្ញុំ។ ដល់ខ្ញុំឆ្លើយត្រឡប់ទៅវិញគឺ មិនមានការចាំបាច់ធ្វើនៅពេលនេះទេ។ អញ្ចឹងខ្លួនឯងជាអ្នកបបួលគេធ្វើ។ គេបានដឹងរឿងនេះយូរហើយ គេអត់មានត្រូវការធ្វើនៅក្នុងពេលនេះទេ។ ខ្លួនឯងបបួលគេធ្វើ ហើយចង់ថាយកអាផែនទីឆ្នាំ១៩១៤។ អត់មានទេផែនទីឆ្នាំ១៩១៤ សូមផ្តាំត្រឡប់ទៅវិញកុំលូងពេក។ អញ្ចឹង ឥឡូវវាចេញមកទាំងអស់ហើយ។ ខ្ញុំព្រះករុណាខ្ញុំបានបញ្ជាក់ប្រាប់អំពីចំណុចទាក់ទិននឹងតំបន់ដាក់ដាំដាក់ហ៊្វិត ព្រោះខ្ញុំព្រះករុណាខ្ញុំ ទ្រាំទ្រលែងកើតជាមួយនឹងការប្រមាថមាក់ងាយសព្វបែបយ៉ាង។

ការចរចាជាមួយវៀតណាមនៅតែបន្តធ្វើ មិនមែនបោះបង់ចោលទេ ដោយយើងបានមើលឃើញសណ្ឋាន អគ្គទេសាភិបាលឥណ្ឌូចិនបានឱ្យដើរតាមព្រែកដាក់ហ៊្វិត។ បន្ថែមលើនោះតាមព្រែកដាក់ហ៊្វិតមានបង្គោលព្រំដែនមួយចំនួន។ ហើយមួយទៀត ទោះបីផែនទីដើរតាមព្រែកដាក់ដាំប៉ុន្តែព្រែកដាក់ដាំពុំមានបង្គោលព្រំដែនទេ។ នេះជាចំណុចដែលកម្ពុជា នៅបន្តការពិភាក្សាជាមួយវៀតណាម។ ប៉ុន្តែសូមបញ្ជាក់ថា យើងមិនអាចលើកកងទ័ពទៅដណ្តើមយកទឹកដីនោះបានទេ វាហួសសម័យហើយ។ យើងមិនអាចធ្វើតាម Abhisit Vejjajiva នៅប្រទេសថៃបានទេ។

2. នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៥ ខ្ញុំព្រះករុណាខ្ញុំ ក៏បានផ្ញើលិខិតផ្ញើទៅមេដឹកនាំប្រទេសមហាអំណាចចំនួន ៣ ទៀត គឺ សាធារណរដ្ឋបារាំង សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ក្នុងគោលដៅស្វះស្វែងរកកិច្ចសហការស្នើសុំខ្ចីផែនទី និងស្នើសុំអ្នកឯកទេសខាងផែនទីដើម្បីផ្ទៀងផ្ទាត់ជាមួយផែនទីផ្លូវការ និងស្របច្បាប់ ខ្នាត ១/១០០ 000 ដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនជាមួយវៀតណាម។ ជាលទ្ធផល ចក្រភពអង់គ្លេស តាមរយៈលិខិតចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ របស់ឯកឧត្តមនាយករដ្ឋមន្ត្រី David CAMERON បានឆ្លើយតបជាផ្លូវការថា ចក្រភពអង់គ្លេសពុំបានរកឃើញនូវផែនទីដូចដែលកម្ពុជាបានស្នើសុំនោះទេ។ ចំណែកឯ សាធារណរដ្ឋបារាំងវិញ តាមរយៈលិខិតចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៥ របស់ឯកឧត្តមប្រធានាធិបតី François HOLLANDE បានឆ្លើយតបជាវិជ្ជមានទៅនឹងសំណើរបស់កម្ពុជា ដោយបានសម្រេចប្រគល់ឱ្យកម្ពុជា នូវច្បាប់ចម្លងនៃផែនទីខ្នាត ១/១០០ 000 បោះពុម្ពដោយ "ក្រុមភូមិសាស្ត្រឥណ្ឌូចិន" ចំនួន ២៦ ផ្ទាំង តាមរយៈស្ថានទូតបារាំងប្រចាំនៅកម្ពុជា។ ដោយឡែក សហរដ្ឋអាមេរិកពុំទាន់បានឆ្លើយតបជាលិខិតផ្លូវការទៅនឹងសំណើរបស់កម្ពុជានៅឡើយទេ។

(សេចក្តីអធិប្បាយបន្ថែម)

*ក៏ប៉ុន្តែ យើងក៏សូមបញ្ជាក់ផងដែរថា ផែនទីរបស់អាមេរិកត្រូវបាន ឯកឧត្តម វ៉ា គឹមហុង ទៅថតយកមកតាំងពីជាង ១០ ឆ្នាំមុននោះ។ ឥឡូវនេះ ក្នុងផ្ទះខ្ញុំព្រះករុណាខ្ញុំ ពោរពេញទៅដោយផែនទីតែម្តង ទាំងផែនទីមកពីបារាំង ទាំងផែនទីមកពីសង្គ្រោះជាតិ ទាំងផែនទីមកពីអាមេរិកទាំងផែនទីមកពីអង្គការ*

*សហប្រជាជាតិ ពោរពេញដោយផែនទី។ អញ្ចឹងផែនទីដែលអ្នកខ្លះអួតអាងបានរកឃើញ ហើយរាជរដ្ឋាភិបាលរកមិនឃើញគេយកមកទុកនៅទីនេះតាំងពីជាង ១០ ឆ្នាំមុននោះ ហើយផ្ទៀងផ្ទាត់ទៅវាអត់មានខុសអីទេ វានៅតែដដែលហ្នឹង។ អញ្ចឹង អាមេរិកឱ្យឬមិនឱ្យ មិនមានការចាំបាច់បន្ថែមទេ។ [...] ពីមុនផ្លូវការទៅហើយ គេបោះត្រាឱ្យចេញពីបណ្ណាល័យហ្នឹងនោះ ប៉ុន្តែយើងចង់ឱ្យពីសំណាក់រដ្ឋាភិបាលមករដ្ឋាភិបាល វាល្អជាង។*

ផ្អែកលើលទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់មកនេះ ដើម្បីសម្របសម្រួលការងារទទួល ប្រគល់ និងផ្ទៀងផ្ទាត់ផែនទី នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៥ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មការចំពោះកិច្ចដែលមានសមាសភាពចំនួន ១១ រូប មកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងដឹកនាំដោយ ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ គណៈកម្មការចំពោះកិច្ចនេះបានធ្វើការយ៉ាងម៉ត់ចត់ ក្នុងលក្ខណៈបើកចំហរ និងប្រកបដោយតម្លាភាពពេញលេញ ដោយមានការចូលរួមត្រួតពិនិត្យនិងសង្កេតការណ៍យ៉ាងទូលំទូលាយពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធ ជាអាទិ៍ តំណាងគណបក្សនយោបាយ តំណាងរដ្ឋសភា តំណាងព្រឹទ្ធសភា តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តំណាងរាជបណ្ឌិតសភាកម្ពុជា ព្រមទាំងទីប្រឹក្សារាជរដ្ឋាភិបាល ដែលមានសញ្ជាតិបរទេសមួយចំនួន ដើម្បីផ្ទៀងផ្ទាត់ផែនទីដែលទទួលបានពីអង្គការសហប្រជាជាតិ និងពីសាធារណរដ្ឋបារាំង។

ការផ្ទៀងផ្ទាត់ផែនទីដើមដែលអង្គការសហប្រជាជាតិបានឱ្យខ្ចីជាមួយផែនទីផ្លូវការ និងស្របច្បាប់របស់ រាជរដ្ឋាភិបាលកម្ពុជាបានប្រព្រឹត្តិទៅនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥។ **លទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទី**

**នេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ដោយគ្មានការសង្ស័យ អំពីភាពត្រឹមត្រូវ ដូចគ្នាបេះបិទរវាងខ្សែ បន្ទាត់ព្រំដែននៃផែនទីដើម ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទី ១ បានប្រើប្រាស់ជាផ្លូវការ ហើយដែលអង្គការសហប្រជាជាតិបានអនុញ្ញាតឱ្យកម្ពុជាខ្ចី ជាមួយនឹងខ្សែបន្ទាត់ព្រំដែន នៃផែនទីផ្លូវការ និងស្របច្បាប់ ដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់សម្រាប់កំណត់និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។**

ការផ្ទៀងផ្ទាត់ផែនទីច្បាប់ចម្លងដែលសាធារណរដ្ឋបារាំងបានប្រគល់ឱ្យជាមួយនឹងផែនទីផ្លូវការនិងស្រប ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា បានប្រព្រឹត្តិទៅនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥។ ខ្ញុំព្រះករុណាខ្ញុំ សូមគូស បញ្ជាក់ឡើងវិញម្តងទៀតថា សាធារណរដ្ឋបារាំង តាមរយៈស្ថានទូតរបស់ខ្លួនប្រចាំនៅកម្ពុជា បានប្រគល់ជូន រាជរដ្ឋាភិបាលកម្ពុជា នូវផែនទីច្បាប់ចម្លងចំនួន ២៦ ផ្ទាំង ដែលទទួលបានពីវិទ្យាស្ថានជាតិភូមិសាស្ត្រ ប្រទេសបារាំង។ ផែនទីទាំង ២៦ ផ្ទាំងនេះ គឺជាផែនទីខ្នាត ១/១០០ ០០០ ដែលធ្វើដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ក្នុងនោះមាន ២៥ ផ្ទាំង ជាប្រភេទផែនទី Bonne និង ១ ផ្ទាំង ជាប្រភេទផែនទី UTM។ ផែនទីនេះ ត្រូវបានធ្វើនៅចន្លោះឆ្នាំ ១៩៣៣ - ១៩៥៣។ ផែនទីដែលទទួលបានពីបារាំងនាពេលនេះ គឺជាផែនទី ដែលមានសារៈសំខាន់បំផុត ពីព្រោះផែនទីនេះផលិតឡើងដោយបារាំង ហើយនៅពេលនោះ បារាំងគឺជាអាណាព្យាបាលលើកម្ពុជា និងជាអ្នកកំណត់ព្រំដែនរវាងកម្ពុជានិងសៀម រវាងកម្ពុជាជាមួយកូសាំងស៊ីន និងរវាងកម្ពុជាជាមួយឡាវ។ ព្រំដែនដែលកំណត់ដោយបារាំងនេះ បានបន្សល់ជាមរតកប្រវត្តិសាស្ត្រ និងជាមូលដ្ឋានដ៏សំខាន់សម្រាប់កម្ពុជាយកមកប្រើប្រាស់ ក្រោយពេលទទួល

បានឯករាជ្យ ស្របតាម "គោលការណ៍ខ្សែព្រំដែនមិនកែប្រែ"។

ជាថ្មីម្តងទៀត លទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីដោយបើកចំហ និងប្រកបដោយតម្លាភាពនេះ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ដោយគ្មានការសង្ស័យ អំពីភាពត្រឹមត្រូវដូចគ្នាបេះបិទ រវាងខ្សែបន្ទាត់ ព្រំដែននៃផែនទីទាំង ២៦ ផ្ទាំងដែលផលិតដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន និងដែលទទួលបានពីបារាំង ជាមួយនឹងខ្សែបន្ទាត់ព្រំដែននៃផែនទីផ្លូវការ និងស្របច្បាប់ទាំង ២៦ ផ្ទាំង ដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងប្រើប្រាស់សម្រាប់កំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។

(សេចក្តីអធិប្បាយបន្ថែម)

*ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់នៅក្នុងចំណុចនេះបន្តិច រវាងផែនទីដែលយកពីអង្គការសហប្រជាជាតិ ១៨ផ្ទាំង ពិតមែនតែជាផែនទី មិនមែនតម្កល់នៅអង្គការសហប្រជាជាតិ ហើយក៏មិនមែនជាផែនទី* Bonne *តែជាផែនទី* UTM *ខ្នាត ១/១០០ ០០០។ ប៉ុន្តែសូមបញ្ជាក់ថា បារាំងបានធ្វើផែនទីទាំង ២ បែប។ ពិតមែនតែខ្ញុំព្រះករុណាខ្ញុំ មិនមែនជាអ្នកឯកទេសផែនទី ក៏ប៉ុន្តែដើម្បីយល់ដឹងអំពីបញ្ហាទឹកដី ខ្ញុំព្រះករុណាខ្ញុំបានស្វះស្វែងសិក្សា ស្វែងយល់អំពីផែនទី។ បារាំងបានធ្វើទាំងផែនទី* Bonne *និងទាំងផែនទី* UTM*។ អញ្ចឹង ផែនទីដែលបានយកពីអង្គការសហប្រជាជាតិ ជាប្រភេទផែនទី* UTM *ប៉ុន្តែយកមកផ្ទៀងផ្ទាត់ជាមួយផែនទី* Bonne *ដែលជាផែនទីដើម ដែលចុះហត្ថលេខារវាងកម្ពុជា និងវៀតណាម គឺដូចគ្នាទាំងស្រុង រាប់ទាំងតំបន់ដាក់ដាំ ដាក់ហ៊ូតនេះតែម្តង គឺដូចគ្នាទាំងស្រុង។ អញ្ចឹងចំណុចនេះ គឺ ទោះ* UTM *ឬ* Bonne *គឺវាដូចគ្នា សម្រាប់មកពីបារាំង។ មកពីអង្គការសហ*

ប្រជាជាតិមិនមែន Bonne ទេ គឺ UTM ប៉ុន្តែគឺបារាំងជាអ្នកធ្វើ។ ធ្វើទាំង ២។ បារាំងមានទាំង២។ ហើយពេលដែលយើងផ្ទៀងផ្ទាត់ជាមួយផែនទី ផែនទីបារាំង គឺជាផែនទីសំខាន់ណាស់ មកពីកន្លែងផ្សេងគឺជារឿងមួយ។ ប៉ុន្តែមកពីបារាំង ដោយសារអ្វី? បារាំងជាអ្នកកំណត់ព្រំដែនឱ្យយើងជាមួយនឹងសៀម កាលពីពេលនោះសៀម ឥឡូវ ថៃ ឱ្យយើងជាមួយកូសាំងស៊ីន ឥឡូវ វៀតណាម ឱ្យយើងជាមួយនឹងឡាវ ឱ្យយើងជាព្រំប្រទល់រដ្ឋបាលរវាងកម្ពុជា និងអាណាម។ ឥឡូវ កូសាំងស៊ីន និងអាណាម ទៅជាវៀតណាមតែមួយ។ អញ្ចឹងសំខាន់ណាស់ ផែនទីមកពីបារាំង។

ខ្ញុំព្រះករុណាខ្ញុំ សូមទូលប្រគេនចំពោះព្រះតេជព្រះគុណ ព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិថា ខ្ញុំព្រះករុណាខ្ញុំ ប្ដេជ្ញាចិត្តរួចហើយថាប្រសិនបើផែនទីមកពីបារាំងខុសគ្នាជាមួយនឹងផែនទីដែលចុះហត្ថលេខាជាមួយនឹងវៀតណាម ខ្ញុំព្រះករុណាខ្ញុំនឹងប្រកាសលាលែងពីតំណែងភ្លាម។ មិនធ្វើជានាយករដ្ឋមន្ត្រីតទៅទៀត ហើយក៏ស្ម័គ្រចិត្តចូលទៅកាន់មន្ទីរឃុំឃាំង រង់ចាំតុលាការកាត់ទោសតែម្ដង។ ព្រោះនេះ ជាការទទួលខុសត្រូវជាប្រវត្តិសាស្ត្រដ៏ធំធេង។ [...] រឿងនេះ ខ្ញុំព្រះករុណាខ្ញុំ បានគិតនៅថ្ងៃទី ០៦ បញ្ជាមកភ្នំពេញ ឱ្យធ្វើលិខិត។ [...] បញ្ជាទាំងជាមួយរដ្ឋមន្ត្រីការបរទេស បញ្ជាមកឯកឧត្ដម អូន ព័ន្ធមុនីរ័ត្ន ក្នុងឋានៈជាប្រធានឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ច ដែលធ្លាប់តែធ្វើឯកសារឱ្យខ្ញុំព្រះករុណាខ្ញុំ ផ្ញើពីភ្នំពេញទៅផង ដើម្បីផ្ទឹមគ្នាទាំង២ទិស ពីក្រសួងការបរទេស និងពីឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ច។ ខ្ញុំព្រះករុណាខ្ញុំ បានចុះហត្ថលេខាតាំងពីយប់ថ្ងៃទី ០៦។ [...]

*ខ្ញុំព្រះករុណាខ្ញុំ ពិតជាប្រថុយប្រថាននឹងគ្រោះថ្នាក់ធំណាស់។ ប្រសិនបើផែនទីមកពីបារាំង បែរជាខុសជាមួយផែនទីដែលចុះហត្ថលេខាជាមួយវៀតណាម ពេលនោះហើយដែល ខ្ញុំព្រះករុណាខ្ញុំ ប្រកាសលាលែងចេញពីតំណែង។ គណបក្សប្រជាជន ត្រូវជ្រើសរើសនូវមេដឹកនាំថ្មី។ នេះជាការដឹងតែខ្ញុំព្រះករុណាខ្ញុំម្នាក់គត់ មិនឱ្យប្រពន្ធ មិនឱ្យកូន និងមិនឱ្យសមាជិកបក្ស មានការភ័យព្រួយទេ។ ចឹងទេ បានជានៅពេលដែលផ្ទៀងពីអង្គការសហប្រជាជាតិ ខ្ញុំព្រះករុណាខ្ញុំ អត់ដាក់កម្មវិធីទៅណាទេ នៅមើលការផ្ទៀង។ ដល់ពេលផ្ទៀងរបស់បារាំង គឺសំខាន់ជាងការផ្ទៀងរបស់មកពីអង្គការសហប្រជាជាតិ ព្រោះមកពីអង្គការសហប្រជាជាតិ គឺជាផែនទីដែលយើងបញ្ជូនទៅប្តឹង ហើយមិនគ្រប់ទៅទៀត បានតែ ១៨ ផ្ទាំង លើ ២៦ផ្ទាំង អញ្ចឹងត្រូវឱ្យគ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់ផ្សាយបន្តផ្ទាល់ បើសិនជាពេលនោះឃើញថា មានការខុសគ្នា ក្នុងពេលដំណាលគ្នា គឺនឹងមានប្រកាសផ្សាយបន្តផ្ទាល់ អំពីការប្រកាសលាលែងពីតំណែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ចប់ការកាន់អំណាចរយៈពេលជាង ៣ទសវត្សរ៍របស់ខ្លួន។ ប៉ុន្តែអ្វីៗបានច្បាស់ហើយ ទេវតាមានភ្នែក។ ទេវតាពិតជាមិនដាក់ទណ្ឌកម្ម ចំពោះអ្នកដែលបានប្រព្រឹត្តនូវអំពើល្អទេ។ ហើយទេវតាបាននឹងកំពុងដាក់បណ្តាសាទៅលើពួកអ្នកដែលបានធ្វើអំពើអាក្រក់អ្នកខ្លះកំពុងរត់ចោលស្រុក អ្នកខ្លះនៅក្នុងមន្ទីរឃុំឃាំង។ នេះ ខ្ញុំព្រះករុណាខ្ញុំសូមទូលប្រគេន និងជម្រាបជូនពីអាថ៌កំបាំងលើរឿងនេះ។ [...] អញ្ចឹងចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ បាននិយាយបញ្ជាក់ជូនជន*

*រួមជាតិ អំពីអ្វីដែលជាអាថ៌កំបាំងលាក់ទុក ដែលខ្ញុំព្រះករុណាខ្ញុំបានទូលប្រគេននេះ។ មួយចានទឹក មួយចានគោក ឬមួយបន្តកាន់អំណាចដោយមានការជឿជាក់ពីសំណាក់ប្រជាពលរដ្ឋ ឬមួយលាលែងចេញពីតំណែង តាមរយៈការផ្ទៀងផ្ទាត់ផែនទីមិនត្រូវគឺត្រូវលាលែងពីតំណែង។ ឥឡូវអ្នកដែលយកមកចោទគេថាផែនទីក្លែងក្លាយ តើហ៊ានលាលែងពីតំណែងឬអត់? នេះជាចម្លើយបកត្រឡប់ទៅវិញ អំពីការទទួលខុសត្រូវរៀងខ្លួន លើមុខប្រវត្តិសាស្ត្ររបស់ជាតិ។ ការភូតកុហកដែលមានចរិកគ្រោះថ្នាក់ឱ្យជាតិ គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ។ ខ្ញុំព្រះករុណាខ្ញុំប្រើពាក្យថា ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយជាឧក្រិដ្ឋជនតែម្ដង។*

បន្ថែមពីលើនេះ ក្នុងគោលដៅធានាឱ្យមានភាពកាន់តែច្បាស់លាស់ជ្រះស្រឡះអស់នូវមន្ទិលសង្ស័យ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តដល់ក្រុមស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលជាស្ថាប័នវិទ្យាសាស្ត្រឯករាជ្យដឹកនាំដោយលោកបណ្ឌិត សុខ ទូច ឱ្យធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាព្រំដែននេះផងដែរ។ ក្រុមស្រាវជ្រាវនេះបានដំណើរការប្រមូលឯកសារពាក់ព័ន្ធនឹងបញ្ហាព្រំដែនប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម ពិសេសផែនទីព្រំដែនរដ្ឋរវាងប្រទេសទាំងពីរពីប្រភពនានា ហើយទទួលបាននូវផែនទីផ្លូវការ ដែលប្រើប្រាស់ដោយរាជរដ្ឋាភិបាលចំនួន ២៦ ផ្ទាំង ផែនទីពីគណបក្សសង្គ្រោះជាតិចំនួន ២៤ ផ្ទាំង ផែនទីពីបណ្ណាល័យព្រឹទ្ធសភាអាមេរិក ចំនួន ២៦ ផ្ទាំង ផែនទីពីអង្គការសហប្រជាជាតិ ចំនួន ១៨ ផ្ទាំង និងផែនទីពី បណ្ណាល័យវិទ្យាស្ថានភូមិសាស្ត្រជាតិ (បារាំង) ចំនួន ២៦ ផ្ទាំង។ ក្រុមស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជាបានធ្វើការផ្ទៀងផ្ទាត់ផែនទីដែលប្រមូលបានទាំងអស់នេះ ដោយមានការចូលរួមពីសមាជិក

**រដ្ឋសភា នៃគណបក្សទាំងពីរ សមាជិកព្រឹទ្ធសភា និងតំណាងរាជរដ្ឋាភិបាល ព្រមទាំងតួអង្គពាក់ព័ន្ធនានា។ លទ្ធផលនៃការផ្ទៀងផ្ទាត់នេះត្រូវបានបង្ហាញឱ្យឃើញតាមរយៈសន្និសីទសារព័ត៌មាន កាលពីថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១៥ ថាផែនទីផ្លូវការដែលរាជរដ្ឋាភិបាលបាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយវៀតណាម គឺជាផែនទីត្រឹមត្រូវច្បាស់លាស់ ហើយផែនទីដែលទទួលបានពីប្រភពនានាដោយរួមទាំងផែនទីទទួលបានពីគណបក្សសង្គ្រោះជាតិផង គឺដូចគ្នាទៅនឹងផែនទីផ្លូវការរបស់រាជរដ្ឋាភិបាល។**

(សេចក្តីអធិប្បាយបន្ថែម)

*ពិតមែនតែ ខ្ញុំព្រះករុណាខ្ញុំ បានហៅថា ផែនទីសង្គ្រោះជាតិ មកពីគណបក្សសង្គ្រោះជាតិ ជាផែនទី ដែលចរិកសាហាវជាងសត្វអសិរពិស គឺចំណុចត្រង់ថា គេលាក់ទុកផែនទីនេះយូរពេក ហើយយកចំណុចនោះទៅបោកប្រាស់ប្រជាជន និងបង្ហោះបន្ទោសបង្អាប់ផែនទីរបស់រាជរដ្ឋាភិបាល។ តែខ្ញុំមិនបានហៅផែនទីរបស់បក្សសង្គ្រោះជាតិជាផែនទីក្លែងក្លាយទេ ព្រោះផែនទីនេះ វាដូចគ្នានឹងផែនទីរបស់រាជរដ្ឋាភិបាលដែរ វានៅខ្វះតែ ២ ផ្ទាំងតែប៉ុណ្ណោះ ហើយសង្ឃឹមថា សង្គ្រោះជាតិ នឹងរកផែនទីទាំង ២ ផ្ទាំងនេះ ទៅជូន ឯកឧត្តម សុខ ទូច។ [...]*

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងនូវមូលវាចាដ៏ថ្លៃថ្លាជូនចំពោះក្រុមស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានធ្វើកិច្ចការងារនេះ ប្រកបដោយវិជ្ជាជីវៈឯករាជ្យភាព និងតម្លាភាពទូលំទូលាយ។ រាជរដ្ឋាភិបាលលើកទឹកចិត្តដល់ក្រុមស្រាវជ្រាវនេះនៃរាជបណ្ឌិត្យសភាកម្ពុជាឱ្យបន្តសកម្មភាពសិក្សាស្រាវ

ជ្រាវនេះតទៅទៀត រួមបញ្ចូលទាំងការពិនិត្យផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវរវាងផែនទី និងបង្គោលព្រំដែនដែលបានបោះហើយផង។

(សេចក្តីអធិប្បាយបន្ថែម)

*ហើយកន្លងទៅ ក៏មានការបង្ហោះតាមហ្វេសប៊ុក ដើម្បីគំរាមសម្លាប់បណ្ឌិត សុខ ទូច។ រាជរដ្ឋាភិបាល ត្រូវមានការទទួលខុសត្រូវហើយស្វែងរកចាប់ជនល្មើសបានហើយផងដែរ ហើយតុលាការកំពុងស្រាវជ្រាវករណីនេះជាបន្ត។*

## IV- **ការសន្និដ្ឋាន និង ការទារបន្ត**

សរុបសេចក្តីទៅ ការពិនិត្យឡើងវិញអំពីសារតា និងទិដ្ឋភាពច្បាប់បានបញ្ជាក់ច្បាស់ថា ផែនទីផ្លូវការ ដែលជាផែនទី Bonne ខ្នាត ១/១០០ ០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣ - ១៩៥៣ ដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងប្រើប្រាស់ ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនជាមួយវៀតណាម គឺជាផែនទីស្របច្បាប់ ពេញលេញ ទាំងតាមច្បាប់ជាតិ ទាំងតាមច្បាប់អន្តរជាតិ។ លើសពីនេះទៀត លទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីក៏បានបង្ហាញឱ្យឃើញយ៉ាងច្បាស់អស់ការសង្ស័យដែរថា ផែនទីដែលអតីតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទី ១ ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋបានប្រើប្រាស់ជាផ្លូវការដើម្បីប្តឹងទៅអង្គការសហប្រជាជាតិនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និងផែនទីបោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិនដែលសាធារណរដ្ឋបារាំងបានប្រគល់ឱ្យរាជរដ្ឋាភិបាលកម្ពុជានោះ គឺមានលក្ខណៈដូចគ្នាបេះបិទទៅនឹងផែនទីផ្លូវការ និងស្របច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងប្រើប្រាស់ ក្នុងការកំណត់ និងការបោះបង្គោល

ព្រំដែនជាមួយវៀតណាម។ លទ្ធផលដូចគ្នាបេះបិទនេះ ត្រូវបានធានាតាមរយៈកិច្ចដំណើរការផ្ទៀងផ្ទាត់ ប្រកបដោយលក្ខណៈបើកចំហរ និងប្រកបដោយតម្លាភាព ពេញលេញនិងទូលំទូលាយ ទោះបីជាការផ្ទៀងផ្ទាត់នេះធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ឬដោយស្ថាប័នឯករាជ្យផ្សេងទៀត ដូចជាក្រុមស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជាក៏ដោយ។

ហេតុនេះ ការចោទប្រកាន់ថា ផែនទីផ្លូវការដែលរាជរដ្ឋាភិបាលបាន និងកំពុងប្រើប្រាស់ក្នុងការ កំណត់ និងការបោះបង្គោលព្រំដែនជាមួយវៀតណាម គឺជាផែនទីក្លែងក្លាយ ឬជាផែនទីមិនត្រឹមត្រូវ ឬរហូត ដល់ថាជា "**ផែនទីចោរ**" ទៀតនោះ គឺជាការមួលបង្កាច់ដោយគ្មានមូលដ្ឋានច្បាស់លាស់ និងយ៉ាងអយុត្តិធម៌ បំផុតមកលើរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។ ការចោទប្រកាន់មួលបង្កាច់ដោយគ្មានការទទួលខុសត្រូវនេះ គឺបានបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីល្បិចកលដ៏ពិសពុល និងការមិនញញើតខ្លាចច្បាប់រដ្ឋរបស់មជ្ឈដ្ឋានប្រឆាំងសំដៅបន្តញុះញង់ បំផុសបំផុល បំភ្លៃ បំផ្លើស កាឡៃការពិត និងសភាពការណ៍ទាក់ទងនឹងបញ្ហាព្រំដែនជាមួយវៀតណាម ដើម្បីបង្កើតឱ្យមានការយល់ដឹងដោយ ភាន់ច្រឡំ និងមិនត្រឹមត្រូវលើបញ្ហាព្រំដែន ក្នុងគោលបំណងបោកបញ្ឆោតទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនប្រជាពលរដ្ឋខ្មែរ ចំពោះជាតិមាតុភូមិជាទីស្នេហារបស់ខ្លួន ដើម្បីគេអាចប្រើប្រាស់ជាឧបករណ៍សម្រាប់ធ្វើ ជាអាជីវកម្មនយោបាយរបស់គេ ដោយមិនខ្វល់ខ្វាយនិងគ្មានការទទួលខុសត្រូវចំពោះជោគវាសនា និងផលប្រយោជន៍របស់ប្រទេសជាតិនោះឡើយ។ **ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលសូមសង្កត់ធ្ងន់ថា ទន្ទឹមនឹងការបន្តលើកស្ទួយ និងគោរពយ៉ាងខ្ជាប់ខ្ជួននូវ**

គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិសេរីភាព របស់ពលរដ្ឋគ្រប់រូបក្នុងការបញ្ចេញមតិ ក៏ដូចជាក្នុងការធ្វើនយោបាយ រាជរដ្ឋាភិបាលក៏នឹងបន្តចាត់វិធានការសមស្រប ដោយគ្មានការលើកលែងប្រកបដោយភាពហ្មឹងម៉ាត់ដាច់ខាត ស្របតាមគោលការណ៍នីតិរដ្ឋ និងវិធាននៃច្បាប់ចំពោះជនទាំងឡាយណាដែលហ៊ានធ្វើសកម្មភាពរំលោភបំពានច្បាប់ នៅក្រោមស្លាកសិទ្ធិនយោបាយនិងសិទ្ធិនៃការបញ្ចេញមតិ។ នៅក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋ អ្នកនយោបាយ ក៏ដូចជា ប្រជាពលរដ្ឋទូទៅអ្នកណាក៏ដោយឱ្យតែប្រព្រឹត្តិល្មើសច្បាប់ គឺត្រូវតែទទួលខុសត្រូវតាមការកំណត់ នៃបទបញ្ញត្តិច្បាប់ គ្មានការលើកលែងនោះទេ។

(សេចក្តីអធិប្បាយបន្ថែម)

*ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ ចាប់ពីពេលនេះតទៅ អ្នកណាក៏ដោយ ដែលហ៊ាននិយាយថា ផែនទីក្លែងក្លាយ ផែនទីមិនត្រឹមត្រូវ ផែនទីចោរ ត្រូវចាប់ខ្លួនបន្ទាន់។ នេះជាបទបញ្ជាដាច់ខាតមួយ ដែលត្រូវតែធ្វើ ព្រោះនេះជាការគ្រោះថ្នាក់សម្រាប់ជាតិ ព្រោះវានឹងបង្កើតឱ្យមានកំហឹងឆាបឆេះ តាមរយៈទឹកចិត្តស្នេហាជាតិរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលស្រលាញ់ទឹកដីរបស់ខ្លួន ហើយត្រូវបានរាជរដ្ឋាភិបាលទៅកាត់ឱ្យបរទេសតាមរយៈផែនទីមិនត្រឹមត្រូវ។ ដូច្នេះ បើទុកឱ្យមានរឿងបែបនេះកើតឡើង សង្គ្រាមវានឹងផ្ទុះ។ ហើយសូមបញ្ជាក់ថា បើខុសពីគណបក្សប្រជាជន គណបក្សដទៃកាន់អំណាច នឹងមានសង្គ្រាមដាច់ខាត។ ខ្ញុំព្រះករុណាខ្ញុំ អះអាងថានឹងមានសង្គ្រាម ព្រោះគេហ៊ានប្រើពីត់ឡូវនូវពាក្យពេចន៍បែបនេះ។*

*ពិតមែនហើយ កាលពីថ្ងៃសុក្រអាទិត្យមុន ក្នុងពេលប្រជុំ*

គណៈរដ្ឋមន្ត្រី មានអ្នកបង្ហោះតាមហ្វេសប៊ុក ថាកុំបន្ទោសខ្មែរគ្នាឯង ព្រោះដីខ្មែរបាត់តាំងពី ៤០០ ឆ្នាំមុននោះ តាំងពីគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ មិនទាន់កើត។ ចុះបើលោកឯងនិយាយអញ្ចឹងដដែល ម្តេចក៏លោកឯងជេរខ្ញុំប៉ុន្មានឆ្នាំមកហើយ? ឥឡូវបកស្រាយហ្វេសប៊ុករបស់លោកឯងមក វាយ៉ាងម៉េចទៅវិញ? ឯកឧត្តម សម រង្ស៊ី តែម្តង គាត់ថាបាត់តាំងពីជំនាន់ជ័យជេដ្ឋាទី ២ ឯណោះ ៤០០ ឆ្នាំមុនឯណោះ តាំងពីគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិមិនទាន់កើត។ អញ្ចឹងអ្នកឯងជេរខ្ញុំប៉ុន្មានឆ្នាំហើយ ទាំងឯកឧត្តមសមរង្ស៊ីផ្ទាល់ និងអ្នកដឹកនាំឯកឧត្តម ទទួលខុសត្រូវបែបណា? បើសារភាពបែបហ្នឹងហើយ ត្រូវហ៊ានទទួលខុសត្រូវបន្តទៀត។ ត្រូវហ៊ានសុំទោសទេ? ហោចណាស់ក៏ត្រូវទទួលខុសត្រូវខាងសីលធម៌ដែរ ដែលយើងបានជេរគេថា លក់ទឹកលក់ដី ធ្វើឱ្យបាត់ដីរាប់ពាន់រាប់ម៉ឺនគីឡូម៉ែត្រការ៉េ។ តើអ្នកឯងហ៊ានទទួលខុសត្រូវទេ? នេះបើចិត្តជាកូនប្រុស ដូចដែលខ្ញុំបាននិយាយអម្បាញ់មិញ បើផ្ទៀងទៅឃើញថាខុស ខ្ញុំលាចេញពីតំណែង។ ឥឡូវលោកឯងហ៊ានទេ? ខ្ញុំសូមគ្រាន់តែបញ្ជាក់ថា ខ្ញុំមិនអត់អោនឱ្យអ្នកណាមួយដែលបន្តប្រើពាក្យផែនទីមិនត្រឹមត្រូវ ផែនទីក្លែងក្លាយ ផែនទីចោរ។ ហើយក៏សូមបញ្ជាក់ បើគេមិនឱ្យខ្ញុំសុខ ខ្ញុំក៏មិនឱ្យគេសុខដែរ។ ខ្ញុំកំពុងតែស្ថិតនៅក្នុងអំណាច ខ្ញុំអត់ទៅធ្វើអ្វីខុសទេ។ តែបើអ្នកឯងប្រើឯកសារក្លែងក្លាយ អ្នកឯងមកចោទគេថា ក្លែងក្លាយដោយទទឹងទិស អ្នកឯងត្រូវទទួលខុសត្រូវចំពោះច្បាប់។ អញ្ចឹង អ្នកអនុវត្តច្បាប់ មន្ត្រីអនុវត្តច្បាប់ទាំងអស់ ត្រូវចាប់ខ្លួននៅនឹងកន្លែង

ចំពោះអ្នកណាក៏ដោយដែលប្រើពាក្យ ភាសានេះ ព្រោះជាការបំពានច្បាប់យ៉ាងពិតប្រាកដ យ៉ាងហោចត្រូវមើលព្រះរាជក្រមប្រកាសដាក់ឱ្យប្រើប្រាស់នូវច្បាប់ទាក់ទងទៅនឹងសន្ធិសញ្ញា និងមានផែនទីនេះ។ នេះជាមូលដ្ឋានដែល ខ្ញុំព្រះករុណាខ្ញុំ ហ៊ានចេញបទបញ្ជា។ ព្រោះបើមិនចេញបទបញ្ជាបែបនេះ គឺអ្នកណាចេញបទបញ្ជាក្រៅពីនាយករដ្ឋមន្ត្រី? អារឿងបទល្មើសដាក់ស្តែងត្រូវតែចាប់ខ្លួនភ្លាម មិនមែនជាការគំរាមកំហែង។ សិទ្ធិនយោបាយត្រូវធ្វើ ក៏ប៉ុន្តែកុំឱ្យឈានដល់កម្រិតការចោទប្រកាន់គេ។ រាជរដ្ឋាភិបាល ខ្លួនខ្ញុំព្រះករុណាខ្ញុំ ក្នុងឋានៈជាប្រមុខនៃរាជរដ្ឋាភិបាលនេះគោរពទាំងស្រុងនូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិ គោរពទាំងស្រុងនូវសកម្មភាពនយោបាយទាំងឡាយណាដែលស្របច្បាប់។ ប៉ុន្តែមិនលើកលែង និងមិនអត់អោនដាច់ខាតជាមួយអ្នកណាក៏ដោយ ដែលនៅបន្តបំពានលើករណីទាក់ទិនជាមួយនឹងបញ្ហាផែនទី និងព្រំដែន។ មិនអាចយោគយល់។

គេធ្លាប់និយាយថា ៖ "យោគយល់ចំពោះសត្រូវ ព្រៃផ្សៃចំពោះខ្លួនឯង" ពិតប្រាកដណាស់រឿងនេះ។ កន្លងទៅ ការយោគយល់របស់ខ្ញុំព្រះករុណាខ្ញុំ បានតែធ្វើបាបត្រឹមខ្លួនឯងប៉ុណ្ណោះ។ លើកលែងទោសឱ្យអ្នកដដែលម្តងហើយម្តងទៀត អ្នកនោះតែងតែមកធ្វើបាបខ្លួនជានិច្ច។ នេះសមនឹងអ្វីដែលគេធ្លាប់និយាយថា "យោគយល់ឱ្យសត្រូវ ព្រៃផ្សៃចំពោះខ្លួនឯង"។ តែខ្ញុំព្រះករុណាខ្ញុំស្មោះស្ម័គ្រធ្វើដោយចិត្តឯង។ តែពីពេលនេះទៅ គឺមិនអាចទេ មិនយោគយល់ដាច់ខាត ចំពោះជម្ងឺដដែលៗ និងមុខមនុស្សដដែលៗ ដែលប្រព្រឹត្តនូវកំហុសដដែលបែបនេះ។ មិនមែនជា

*ការគំរាមកំហែងមួយទេ។ ក៏ប៉ុន្តែប្រជាធិបតេយ្យ ត្រូវអមដោយនីតិរដ្ឋ មិនអាចបំពាននីតិរដ្ឋបានទេ។ អនុវត្តច្បាប់ដោយគ្មានការលើកលែង ទោះអ្នកនោះជាអ្នកណាក៏ដោយ។*

តទៅមុខទៀត រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា នៅតែបន្តការប្តេជ្ញាចិត្ត ដ៏មោះមុតឥតងាករេ ក្នុងការអនុវត្តន៍គោលនយោបាយរបស់ខ្លួន សំដៅកសាងឱ្យបាននូវខ្សែបន្ទាត់ព្រំដែនមួយ ស្អាត និងអចិន្ត្រៃយ៍ជាមួយប្រទេសជិតខាង ប្រកបដោយភាពច្បាស់លាស់ត្រឹមត្រូវ សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ និងធានាឱ្យបានជាដាច់ខាតថា បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជានឹងមិនបាត់បង់ឡើយ សូម្បីតែមួយម៉ែត្រក្រឡាក៏ដោយ។ លើមូលដ្ឋាននៃគោលនយោបាយនេះ, រាជរដ្ឋាភិបាលនឹងបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយសង្គត្តិភាព នូវគោលការណ៍ជាយុទ្ធសាស្ត្រមួយចំនួននៅក្នុងការខិតខំដោះស្រាយបញ្ហាព្រំដែនជាមួយនឹងប្រទេសជិតខាងរួមមាន ៖

ទីមួយ - ធានាការពារឱ្យបានដាច់ខាតនូវអធិបតេយ្យភាព និងបូរណភាពទឹកដី ដោយឈរលើគោលការណ៍ជាមូលដ្ឋាននៃ *"ខ្សែព្រំដែនមិនកែប្រែនៅពេលដែលកម្ពុជាបានឯករាជ្យ"* ដូចមានកំណត់ ក្នុងមាត្រា ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមចំណុច II មាត្រាទី ១ ឃ នៃកិច្ចព្រមព្រៀងប៉ារីស ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១។

(សេចក្តីអធិប្បាយបន្ថែម)

*ខ្ញុំព្រះករុណាខ្ញុំ ក៏ចង់ឆ្លៀតយកឱកាសនេះដើម្បីបង្ហាញបន្តិចអំពីបញ្ហាពាក់ព័ន្ធជាមួយនឹងបញ្ហាកិច្ចព្រមព្រៀងប៉ារីស*

ដែលមនុស្សមួយចំនួនតែងទន្ទិញចាំមាត់ ក្នុងពេលដែលខ្ញុំព្រះករុណាខ្ញុំផ្ទាល់ខ្លួននេះឯង ដែលជាអ្នកចរចាយ៉ាងម៉ឺងម៉ាត់ដាច់ខាត ហើយគឺជាអ្នកដែលបានរួមចំណែកតាំងពីដើមទី ដើម្បីសម្រេចបានកិច្ចព្រមព្រៀងមួយនេះ។ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ថា ចំណុច ឃ ទាក់ទិនជាមួយនឹងបញ្ហាបញ្ចប់សន្និសីញ្ញាដើម្បីឱ្យឃើញទាំងអស់គ្នា។ ត្រង់ចំណុច ឃ នេះ គេបានបញ្ជាក់"បញ្ចប់សន្និសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលមិនស្របទៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន"។ អញ្ចឹង ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ជូនត្រង់ចំណុចនេះបន្តិចប្រសិនបើរដ្ឋធម្មនុញ្ញកម្ពុជាបានចេញមកថា អធិបតេយ្យភាពរបស់កម្ពុជាប្រើប្រាស់តាមផែនទីខ្នាត ១/៥០ ០០០ កិច្ចព្រមព្រៀងនេះរលាយជាស្វ័យប្រវត្តិ។ ប៉ុន្តែហេតុអ្វីបានជាកិច្ចព្រមព្រៀងនេះ វានៅស្ថិតស្ថេរ? ដោយសាររដ្ឋធម្មនុញ្ញរបស់យើង បានកំណត់ថា "ព្រះរាជាណាចក្រកម្ពុជាប្រើប្រាស់ខ្នាតផែនទី ១/ ១០០ ០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣ ដល់ឆ្នាំ ១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ដោយអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣ ដល់ឆ្នាំ ១៩៦៩"។ អញ្ចឹង កិច្ចព្រមព្រៀងនោះ វាស្របទៅនឹងរដ្ឋធម្មនុញ្ញនេះឯង។ វាអត់មានខុស។ ប៉ុន្តែបើរដ្ឋធម្មនុញ្ញចេញមកថាឱ្យប្រើផែនទីខ្នាត ១/៥០ ០០០ ឬ ខ្នាត ១/ ២០០ ០០០ ខុសទៅនឹងអានេះ គឺបានសេចក្តីថា កិច្ចព្រមព្រៀងនេះរលាយជាស្វ័យប្រវត្តិ។

ចូងកាត់មកដល់ព្រះរាជាណាចក្រកម្ពុជាទី ២ ឯកសារនេះមិនមែនជាឯកសាររបស់អតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា

*ទៀតទេ។ មិនមែនជាឯកសាររបស់រដ្ឋកម្ពុជាទៀតទេ។ តែជាឯកសារផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាទី ២។ ខ្ញុំសូមស្នើឱ្យអ្នកច្បាប់ទាំងឡាយ ក៏ដូចជាអ្នកសិក្សាទាំងឡាយអាននូវភាគទី១ ការរៀបចំក្នុងដំណាក់កាលអន្តរកាល ផ្នែកទី ១ ដំណាក់កាលអន្តរកាល និងមាត្រាទី ១ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីងាយយល់ ព្រោះអ្នកខ្លះអត់ដឹងកិច្ចព្រមព្រៀងទីក្រុងប៉ារីសបែរមុខទៅណា ក៏ហ៊ានមកនិយាយផ្ញើឯងជាខ្លាំងពូកែ។ ខ្ញុំអានចំណុចនេះឱ្យបានច្បាស់បន្តិច មាត្រាទី ១ ដើម្បីបម្រើវត្ថុបំណងនៃកិច្ចព្រមព្រៀងនេះ ដំណាក់កាលអន្តរកាលត្រូវចាប់ផ្តើមពីពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយត្រូវបញ្ចប់នៅពេលដែលសភាធម្មនុញ្ញ ដែលបានជាប់ឆ្នោតតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដែលរៀបចំឡើង និងបញ្ជាក់ដោយអង្គការសហប្រជាជាតិ និងអនុម័តរដ្ឋធម្មនុញ្ញ ហើយបានក្លាយខ្លួនទៅជាសភានីតិបញ្ញត្តិ រួចបន្ទាប់មករដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើង។ អញ្ចឹង ឥឡូវនេះ ៥ អាណត្តិហើយ ដែលកិច្ចព្រមព្រៀងនេះបានបន្ត។*

*សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ទៅ [...] វៀតណាម។ បន្ថែមមកទៀត សម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ ក្នុងឋានៈជាព្រះប្រធានរដ្ឋសភានៅពេលនោះ និងក្នុងនាមហ៊ុនស៊ិនប៉ិចនៅពេលនោះ ព្រះមហាក្សត្រយើងបានឡាយព្រះហស្តលេខាលើអ្វីដែលកំពុងមានសព្វថ្ងៃ មិនមែនជារបស់អតីតរដ្ឋកម្ពុជាតទៅទៀតទេ គឺជារបស់ព្រះរាជាណាចក្រដែលស្របនឹងរដ្ឋធម្មនុញ្ញ។ ហើយសូមកុំភាន់ច្រឡំទៅលើការបន្តអនុវត្តកិច្ចព្រមព្រៀងទីក្រុង*

ប៉ារីស តទៅទៀត។ ជាតុនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសទាំងអស់បានចូលមកក្នុងរដ្ឋធម្មនុញ្ញកម្ពុជារួចអស់ទៅហើយ។ កុំភាន់ច្រឡំ ព្រោះមានមនុស្សមួយចំនួនចូលចិត្តនិយាយយ៉ាងពេញៗមាត់ទៅលើកិច្ចព្រមព្រៀងក្រុងប៉ារីស ដោយមិនដឹងថាកិច្ចព្រមព្រៀងក្រុងប៉ារីសចែងពីអ្វី។ តើនៅក្រោមអាណានិគមរបស់អង្គការសហប្រជាជាតិ រហូតឬយ៉ាងម៉េច? គេបានកំណត់យ៉ាងច្បាស់ក្នុងមាត្រា ១។ នៅពេលណាដែលមានការបោះឆ្នោតហើយសភាធម្មនុញ្ញធ្វើរដ្ឋធម្មនុញ្ញហើយ សភាហ្នឹងក្លាយទៅជាសភានីតិបញ្ញត្តិ។ មានរដ្ឋាភិបាលហើយ បានសេចក្តីថា ប្រតិបត្តិការរបស់អង្គការសហប្រជាជាតិត្រូវបញ្ចប់ហើយ។ Akashi, សាតទ្រី, Sanderson ចេញតាំងពីយប់អាធ្រាតថ្ងៃទី២៤ ខែកញ្ញា បន្ទាប់ពីរដ្ឋធម្មនុញ្ញបានប្រកាសឱ្យប្រើ។ នេះត្រូវឱ្យឃើញ។ អ្នកដែលនិយាយអំពីបញ្ហានេះ ត្រូវមើលតម្លៃនៃកិច្ចព្រមព្រៀងប៉ារីសពេលនោះ តើវាស្មើគ្នានឹងតម្លៃរដ្ឋធម្មនុញ្ញ និងតម្លៃនៃព្រះរាជក្រមដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ និងដែលមាននីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ហើយ ៥ អាណត្តិរួចមកហើយ... គឺ បួនអាណត្តិកន្លះ ចាត់ទុកថា ប្រាំអាណត្តិទៅហើយ។ សូមកុំភាន់ច្រឡំតទៅទៀត។ មិនមែនជារបស់គណបក្សប្រជាជន តែជារបស់ជាតិកម្ពុជាទាំងមូល។ អញ្ចឹង សូមឱ្យភ្លឺភ្នែក។ សូមឱ្យសិក្សា អ្នកដែលនិយាយពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស អានកិច្ចព្រមព្រៀងទីក្រុងប៉ារីសពីដើមរហូតដល់ចប់។ ហើយដំបូងបំផុត សូមមើលមាត្រា ១ ភាគទី១ ការរៀបចំក្នុងដំណាក់កាលអន្តរកាល។ គេចង់នៅក្នុងហ្នឹង ដើម្បីជៀសវាង

*អង្គការសហប្រជាជាតិដាក់អាណានិគមមួយជីវិត។ វាបញ្ចប់ត្រឹមពេលដែលគេមានសភា គេមានរដ្ឋធម្មនុញ្ញ គេមានស្អីៗរបស់គេ គឺវាចប់ទៅហើយ។ ឥឡូវ គេមិនចាំបាច់ទៅសុំច្បាប់អ៊ុនតាក់ អីណា។ មិនចាត់ SNC ឱ្យមានបន្ដទៅទៀតឯណា។ SNC ខ្វះនៅឯគុក។ SNC ខៀវ សំផន នៅក្នុងគុកនៅឡើយ។ និយាយរួម SNC ស្លាប់អស់ប្រហែលជាពាក់កណ្ដាលហើយ។ មករកស្អីទៀត។ មិនប្រើរដ្ឋធម្មនុញ្ញរបស់ខ្លួន ទៅប្រើកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ហើយយកមកឱ្យឯង ដើម្បីដើរបោកប្រជារាស្ដ្រ។*

ទីពីរ-ដោយឈរលើមូលដ្ឋាននៃគោលការណ៍ទីមួយខាងលើធានាឱ្យកម្ពុជាមានខ្សែព្រំដែនមួយច្បាស់លាស់ ដោយប្រែក្លាយខ្សែព្រំដែនដែលមានតែនៅលើផែនទីឱ្យទៅជាបង្គោលព្រំដែននៅលើដីជាក់ស្ដែង ហើយខ្សែព្រំដែននេះទៀតសោត នៅពេលណាដែលភាគីទាំងសងខាងបញ្ចប់ការងារបោះបង្គោល និងខណ្ឌសីមាព្រំដែនរួចរាល់ហើយ គឺត្រូវស្របគ្នាទៅនឹងការកាន់កាប់ជាក់ស្ដែងរបស់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្ដោយព្រំដែនទាំងសងខាង។

ទីបី - អនុវត្តការងារនៅក្នុងចំណុចទីពីរខាងលើ ក្នុងស្មារតីសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការសម្រុះសម្រួល ក្នុងឋានៈជារដ្ឋអធិបតេយ្យដែលជាដៃគូស្មើភាព និងស្មើសិទ្ធិជាមួយគ្នា ដោយឈរលើមូលដ្ឋាននៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ទីបួន - កសាងព្រំដែនកម្ពុជាជាមួយប្រទេសជិតខាងឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ដែលនឹងផ្ដល់ផលប្រយោជន៍ដ៏ពិតប្រាកដដល់ប្រទេស និងប្រជាជន ដែលចូលរួមពាក់ព័ន្ធ ទាំងអស់ ពិសេសគឺប្រជាពលរដ្ឋដែលរស់នៅតាមបណ្ដោយព្រំដែន។

(សេចក្តីអធិប្បាយបន្ថែម)

*ឥឡូវ ខ្ញុំព្រះករុណាខ្ញុំ ចង់សួរប្រជាពលរដ្ឋដែលរស់នៅតាមព្រំដែន។ តើចង់បានសង្គ្រាមឬទេ? ខ្ញុំព្រះករុណាខ្ញុំយល់ថា បើសិនសង្គ្រាមផ្ទុះតាមទល់ដែន មិនថាទល់ដែនខាងកើត ឬទល់ដែនខាងលិច ឬទល់ដែនណាទេ ឬមិនថាទូទាំងព្រំដែនទេ សូម្បីតែចំណុចតូចណាមួយក៏ដោយ គឺវាមិនល្អសម្រាប់ប្រទេសជាតិទាំងមូល។*

*ការអភិវឌ្ឍន៍បានប្រទេសជាតិមួយ ចំណុចរបស់វា មានកត្តាអនុគ្រោះផ្ទៃក្នុង និងកត្តាអនុគ្រោះអន្តរជាតិ ដោយរាប់ទាំងទំនាក់ទំនងជិតខាងល្អ។ ការធ្វើពាណិជ្ជកម្មរវាងព្រំដែន កម្ពុជា និងថៃ មានទំហំជាង៥៤០០ លានដុល្លារសហរដ្ឋអាមេរិកកាលពីឆ្នាំទៅ។ ការធ្វើពាណិជ្ជកម្មរវាងព្រំដែនកម្ពុជា និងវៀតណាម ជិត ៤០០០ លានដុល្លារសហរដ្ឋអាមេរិកកាលពីឆ្នាំទៅ។ ជាមួយឡាវ គឺតូចល្មមទេ។ ប៉ុន្តែ ប្រសិនបើប្រទេសទាំងពីរមានជម្លោះជាមួយគ្នា តើប្រជាជនអាចរស់នៅបាន ក្រៅតែពីរត់លូនទេ? យើងធ្លាប់បានឃើញប្រជាជនភៀសសឹកនៅតំបន់ព្រះវិហារធ្លាប់បានឃើញប្រជាជនភៀសសឹកនៅឧត្តរមានជ័យទេ? នេះហើយជាលទ្ធផលនៃសង្គ្រាម។ ហើយនេះហើយជាលទ្ធផលដែលវានឹងមកដល់ នៅពេលដែលគណបក្សប្រឆាំងកាន់អំណាច វានឹងមកដល់នៅពេលដែលគណបក្សប្រជាជនមិនកាន់អំណាចតទៅទៀត។ វាច្បាស់ជាមកដល់។ បក្សដទៃកាន់អំណាច ច្បាស់ណាស់ថា សង្គ្រាមវាកើត។ ខ្ញុំព្រះករុណាខ្ញុំនិយាយពេញមាត់ មានតែគណបក្សប្រជាជនមួយគត់ដែលធានាថា គ្មានជម្លោះទល់ដែន*

*ជាមួយប្រទេសជិតខាង លើកលែងតែប្រទេសជិតខាង លើកទ័ពចូលមកកម្ពុជា ម្តងម្កាលដូចដែលករណីវត្តកែវសិក្ខាគិរីស្វារៈ បង្ខំចិត្តត្រូវតែធ្វើការតស៊ូប្រដាប់អាវុធ។ ទីនេះហើយ ដែលខ្ញុំព្រះករុណាខ្ញុំអង្គុយបញ្ជាតាម* Video Conference *ទៅកាន់ព្រំដែន។ យើងមិនចង់ឃើញស្ថានភាពបែបនេះ។ មានការស្លាប់ មានការរបួស មានការខូចខាតទ្រព្យសម្បត្តិសម្រាប់ប្រជាពលរដ្ឋ។ ខ្ញុំព្រះករុណាខ្ញុំជឿជាក់ថា មិនត្រឹមតែប្រជាពលរដ្ឋនៅតាមព្រំដែនទេ ប្រជាពលរដ្ឋនៅទូទាំងប្រទេស ព្រោះនៅពេលដែលសភាពការណ៍កើតឡើង មិនមែនគ្រាន់តែប៉ះពាល់ដល់ប្រជាជននៅតាមព្រំដែនទេ ប្រជាជននៅទូទាំងផ្ទៃប្រទេស គឺប៉ះពាល់ទាំងអស់។ សូម្បីតែអ្នកធ្វើខាងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច សិល្បករ សិល្បការិនី កីឡាករ កីឡាការិនី ក៏ប៉ះពាល់ទាំងអស់។ សូមកុំសង្ឃឹមបក្សប្រឆាំងដែលគេចិញ្ចឹមចិត្តប្រឆាំងទៅលើបញ្ហា។ ហើយជំងឺជាតិសាសន៍និយមជ្រុលរបស់ពួកគេ ធ្ងន់ធ្ងរខ្លាំងពេកហើយ។*

ក្នុងក្របខ័ណ្ឌនៃគោលនយោបាយ និងគោលការណ៍ជាយុទ្ធសាស្ត្រនេះ ចំពោះការងារចរចា កំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការងារជាក់ស្តែងដែលនៅសេសសល់មួយចំនួន ដូចខាងក្រោម ៖

ទី១ - បន្តការចរចារហូតដល់ចប់សព្វគ្រប់ លើការកំណត់ និងការបោះបង្គោលព្រំដែនដោយហ្មត់ចត់ និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ដោយឈរលើគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងលិខិតូបករណ៍ពាក់ព័ន្ធ រួមទាំងផែនទីស្របច្បាប់ និងផ្លូវការដែលមានជាធរមាននិងដោយប្រើប្រាស់យន្តការ នៃស្ថាប័នមានសមត្ថកិច្ចជាធរមាន។ ក្នុង

បរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងជាមួយភាគី វៀតណាមរួចហើយ ដើម្បីដោះស្រាយករណីដែលអាចមានការមិនឯកភាពគ្នាផ្នែកបច្ចេកទេស ឬមានភាព មិនច្បាស់លាស់លើចំណុចណាមួយនៃផែនទីតាមរយៈការស្រុះស្រួលគ្នារវាងភាគីទាំងពីរ ក្នុងការស្នើសុំ ឬ ជួលអ្នកជំនាញការបរទេសដែលឯករាជ្យឱ្យមកជួយពិនិត្យផ្ទៀងផ្ទាត់ឬផ្តល់ការបំភ្លឺតាមការចាំបាច់។

(សេចក្តីអធិប្បាយបន្ថែម)

*ខ្ញុំព្រះករុណាខ្ញុំ បានលើកជាមួយនឹងបេសកជនពិសេសរបស់វៀតណាម ហើយអាទិត្យមុននេះ ក្នុងពេលប្រជុំគណៈរដ្ឋមន្ត្រី ខ្ញុំព្រះករុណាខ្ញុំ បានណែនាំចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី វ៉ា គឹមហុង ប្រធានគណៈកម្មាធិការចម្រុះព្រំដែន ដើម្បីធ្វើឱ្យមានការចរចាជាមួយវៀតណាមពិតប្រាកដ និងឱ្យមានកំណត់ហេតុ។ ចំណុចណាដែលមិនចុះសម្រុងគ្នាលើបញ្ហាបច្ចេកទេសក្នុងនោះមានទាំងការផ្ទេរពីផែនទី* Bonne *ទៅកាន់ផែនទី* UTM *ត្រូវរកការជួល ឬសុំអ្នកបច្ចេកទេសពីបរទេស។ បើសិនសុំបានជាការល្អ ដូចជាបារាំង។ ប្រធានាធិបតីបារាំងបាននិយាយថា មិនអាចជូនអ្នកបច្ចេកទេសមកបានទេ វៀរលែងតែភាគីទាំងពីរស្នើសុំ។ បើដូច្នោះ យើងក៏ត្រូវឆ្លៀតប្រើនូវសម្តីរបស់ប្រធានាធិបតីបារាំង* François HOLLANDE *អំពីចំណុចនេះ។ អញ្ចឹងយើង និងវៀតណាម រួមគ្នាស្នើសុំអ្នកបច្ចេកទេសផែនទី ដើម្បីមកពិនិត្យ។ ហើយច្បាស់ណាស់ថា ទាំងការជួលគេ ទាំងគេឱ្យប្រហែលជាខ្លះគេអាចឱ្យជាជំនួយឥតសំណង ខ្លះគេអាចឱ្យយើងជាអ្នកបច្ចេកទេស ប៉ុន្តែឱ្យយើងជាអ្នកទទួលបន្ទុកចំណាយ។ ខ្ញុំព្រះ*

*ករុណាខ្ញុំ ឱ្យគោលការណ៍ទៀត! ចែកគ្នាចាយពាក់កណ្ដាលម្នាក់ៗ វៀតណាមចំណាយពាក់កណ្ដាល កម្ពុជាចំណាយពាក់កណ្ដាល រាប់ទាំងថ្លៃសំបុត្រយន្តហោះ អ្នកនោះជិះ ដេកអូតែល។ អស់ប៉ុន្មាន? ឧទាហរណ៍ថា អស់ ១០ ម៉ឺនដុល្លារ! ចេញ ៥ ម៉ឺនដុល្លារម្នាក់ៗ កុំខ្លាចអស់លុយ។ បញ្ហាទឹកដីជាបញ្ហាសំខាន់ បញ្ហាលុយកាក់វាជារឿងសំខាន់ហើយ តែវាមិនសំខាន់ជាងរឿងទឹកដី ដែលដូនតាទុកឱ្យទេ។*

ទី២ - បន្តការផ្ទៀងផ្ទាត់រវាងផែនទី និងបង្គោលព្រំដែនដែលបានបោះរួចជាក់ស្ដែង ដោយហ្មត់ចត់ និងប្រកបដោយតម្លាភាព ដើម្បីធានាភាពត្រឹមត្រូវច្បាស់លាស់ពិតប្រាកដ ទន្ទឹមនឹងការធានានូវភាពរឹងមាំ និងភាពជឿទុកចិត្តបាននៃបង្គោលព្រំដែន។ ការផ្លាស់បង្គោលចាស់ជំនួសដោយបង្គោលថ្មី ដែលរឹងមាំល្អ ក៏ដូចជាការកំណត់ និងការបោះបង្គោលថ្មីត្រូវអនុវត្តស្របតាមនីតិវិធីប្រកបដោយតម្លាភាពបំផុត។

(សេចក្ដីអធិប្បាយបន្ថែម)

*ចំណុចនេះត្រូវធ្វើ កុំឱ្យផែនទីដើរទៅតាមផ្លូវម្ខាង បង្គោលព្រំដែនទៅតាមផ្លូវម្ខាង។ បារាំងធ្លាប់ធ្វើបែបនេះ។ សេចក្ដីសម្រេចរបស់អគ្គទេសាភិបាលតណ្ឌូចិនឱ្យដើរតាមផ្លូវព្រែកដាក់ហ៊្វូត ប៉ុន្តែដល់ទៅគូសផែនទីតាមព្រែកដាក់ដាំ ដល់បោះបង្គោល បោះតាមព្រែកដាក់ហ៊្វូត។ បារាំងធ្លាប់ធ្វើ។ អាហ្នឹងជាចំណុចដែលខ្ញុំចំណាំបាន ដែលខ្ញុំស្គាល់វា ដែលខ្ញុំដឹងវា។ ចំណុចមួយទៀត បង្គោល ៣១៤ ដែលយើងបោះចុងក្រោយ។ បារាំងខ្ជិល! បារាំងបោះកាលពីសម័យដើម គឺបារាំងខ្ជិល។ បោះអត់ត្រូវតាមចំណុចផែនទីទេ។ អញ្ចឹងបានជាពីរវាងបង្គោលចាស់ និងបង្គោលថ្មី គឺ*

*មានចំណុចខុសគ្នា ដោយយើងរុករកទាល់តែឃើញចំណុច ទើបយើងបោះ។ បង្គោលនោះជាបង្គោលចាស់។ អញ្ចឹង វៀតណាមក៏មិនខាត កម្ពុជាក៏មិនចំណេញ។ តែយើងបានធ្វើ audit ឡើងវិញតែប៉ុណ្ណោះ ព្រោះកន្លែងដែលយើងបោះឆ្នាំ ២០១២ ត្រូវចាក់ដីច្រើនណាស់។ ពេលនោះ បារាំងអត់ព្រមចាក់ដីទៅបោះបង្គោលនៅកន្លែងផ្សេង ដែលធ្វើឱ្យគម្លាតព្រំដែនចូលមកក្នុងដីយើងវិញ។ ពេលនោះ វៀតណាមមិនមែនបាត់ដីទេ គ្រាន់តែយើងយកបង្គោលនោះទៅបោះឱ្យចំនឹងកន្លែងដើម។ បង្គោលថ្មីដែលយើងយកបោះជាមួយវៀតណាម ក៏ត្រូវឱ្យមានភាពត្រឹមត្រូវរវាងផែនទីជាមួយនឹងបង្គោលជាក់ស្ដែង។ បើទោះបីជាមានការហត់នឿយបន្តិច ក៏យើងត្រូវតែរួមគ្នាដើម្បីលើកបង្គោលហ្នឹងទៅដាក់នៅកន្លែងដែលត្រឹមត្រូវ។ បង្គោលមួយចំនួនបោះតាំងពីឆ្នាំមួយពាន់ប្រាំបីរយប៉ែតប្វាយ វាចាស់ទៅហើយ។ បើដាក់ទៅវិញ ក៏ត្រូវធ្វើនីតិវិធីឱ្យបានត្រឹមត្រូវ និងមានតម្លាភាព។ អញ្ចឹងចំណុចនេះ គឺផ្ទៀងផ្ទាត់ឱ្យបានច្បាស់រវាងផែនទី ជាមួយនឹងដីជាក់ស្ដែង។ ឥឡូវ ផែនទីចាត់ទុកជាដូចរឿងចប់ទៅហើយ មិនចាំបាច់ទៅផ្ទៀងជាមួយអ្នកណាទៀតទេ ព្រោះអាផែនទីនេះ វាផ្លូវការហើយ។ អ្នកណាហ៊ាននិយាយផែនទីក្លែងក្លាយ គឺអនុវត្តច្បាប់ទៅ។ ប៉ុន្តែបញ្ហាដែលស្ថិតនៅ គឺបញ្ហាបោះបង្គោល។*

ទី៣ - បន្តការចរចាជាមួយភាគីវៀតណាម ដោយហ្មត់ចត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុត លើបណ្ដាចំណុចដែលមិនទាន់ដាច់ស្រេចទាំងឡាយ និងលើតំបន់ដែលត្រូវដោះដូរដោយឈរលើគោលការណ៍ "ស្មើទៅ - ស្មើមក" ទៅតាមលក្ខណៈភូមិសាស្ត្រ និងស្ថានភាពដី

ស្របតាមការអនុញ្ញាត នៃសន្ធិសញ្ញាបំពេញបន្ថែម និងអនុស្សរណៈយោគយល់គ្នា ឆ្នាំ ២០១១។ គោលការណ៍គន្លឹះនៅទីនេះ គឺធានាឱ្យបានដាច់ខាតថា កម្ពុជានឹងមិនបាត់បង់ទឹកដីរបស់ខ្លួនឡើយ សូម្បីតែ ១ ម៉ែត្រក្រឡាក៏ដោយ។ ខណៈដែលការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនមិនទាន់ត្រូវបានបញ្ចប់ទាំងស្រុងនោះទេ រាជរដ្ឋាភិបាល នឹងបន្តធានាឱ្យបានល្អប្រសើរនូវកិច្ចសហការខ្ជាប់ខ្ជួនជាមួយភាគីវៀតណាមក្នុងការរក្សាស្ថានភាពនៃការគ្រប់គ្រង តាមអ្វីដែលមានក្នុងពេលបច្ចុប្បន្ននៅតាមខ្សែបន្ទាត់ព្រំដែន ស្របតាមសេចក្តីប្រកាសរួម ចុះថ្ងៃ ទី ១៧ ខែ មករា ឆ្នាំ ១៩៩៥។

(សេចក្តីអធិប្បាយបន្ថែម)

*ចំណុចនេះខ្ញុំសូមបញ្ជាក់បន្តិច អនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ ២០១១ អនុញ្ញាតឱ្យយើងធ្វើការដោះដូរ មួយទៅមួយមក។ មូលហេតុគឺងាយយល់យ៉ាងដូច្នេះ។ កន្លែងខ្លះបារាំងគូសផែនទី យកភូមិខ្មែរដាក់ឱ្យទៅវៀតណាម។ កន្លែងខ្លះបារាំងគូសផែនទី យកដីវៀតណាមដាក់មកនៅខាងខ្មែរ។ អញ្ចឹងបើសិនជាយើងរើភូមិរបស់កម្ពុជាចេញមកក្នុងដីខ្មែរ ឬកាត់ភូមិនោះទៅឱ្យវៀតណាម គឺមិនសមស្របទេ។ ដូចការដាក់ស្តែងភូមិថ្មកត្រាច របស់សម្តេច ហេង សំរិន ត្រូវរកវិធីដោះដូរដីកន្លែងផ្សេង ដើម្បីរក្សាទុកនៅភូមិរបស់សម្តេច ហេង សំរិន។ ដូច្នេះ គោលការណ៍មួយទៅមួយមកនេះ ត្រូវធ្វើឱ្យបានច្បាស់។ នេះទាមទារនូវភាពម៉ត់ចត់។ ធ្វើយ៉ាងដូច្នេះដើម្បីធានាថា ដីដែលប្រជាពលរដ្ឋកំពុងបង្កបង្កើនផល និងភូមិករបស់ពួកគាត់មិនត្រូវបានបាត់បង់ទេ។*

*វៀតណាមត្រូវរកដីឱ្យយើង យើងត្រូវរកដីឱ្យវៀតណាម នៅកន្លែងផ្សេង។ ដំបូងបំផុត យើងបានឯកភាពគ្នាជាមួយវៀតណាម រកក្នុងក្របខណ្ឌខេត្ត។ បើរកក្នុងក្របខណ្ឌខេត្តមិនបាន ត្រូវរកនៅកន្លែងផ្សេង ធានាឱ្យផ្ទៃក្រឡាទៅវិញទៅមក ទំហំប៉ុនគ្នា។ មួយទៀត ចំណុចទាំង ៧ ដែលនៅសេសសល់ ដែលមានក្នុងលិខិតរបស់ខ្ញុំជូនទៅនាយករដ្ឋមន្ត្រីវៀតណាម នៅតែជាប្រធានបទបន្តការពិភាក្សា នៃគណៈកម្មាធិការចម្រុះព្រំដែនកម្ពុជា-វៀតណាម ដែលក្នុងនោះ មានទាំងតំបន់ដាក់ដាំ ដាក់ហ៊្វិតផងដែរ។*

*ព្រមពេលដែលយើងបន្តការងារបោះខណ្ឌសីមា បោះបង្គោលព្រំដែនមិនទាន់ចប់ទេ ត្រូវខិតខំសហការជាមួយភាគីវៀតណាមទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រក្សាស្ថានភាពដដែលនៅតាមតំបន់ព្រំដែន។ ត្រូវធ្វើនូវកិច្ចការងារនេះតាមរយៈនៃកិច្ចសហប្រតិបត្តិការល្អ មិនមែនគ្រាន់តែព្រំដែនជាមួយវៀតណាមទេ ព្រំដែនជាមួយថៃ ព្រំដែនជាមួយឡាវក៏ត្រូវធ្វើដូចគ្នា។*

*- សម្ដេចព្រះសង្ឃរាជទាំងពីរគណៈជាទីសក្ការៈ*

*- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ*

*- ជនរួមជាតិកម្ពុជាគ្រប់រូបជាទីគោរពស្នេហា!*

ខ្ញុំព្រះករុណាខ្ញុំពិតជាយល់ច្បាស់ដោយគ្មានការស្រមើស្រមៃទេថា អ្នកនយោបាយប្រឆាំងនឹងនៅតែបន្តយកបញ្ហាព្រំដែន ដែលជាបញ្ហាសើបបំផុតសម្រាប់ប្រទេសជាតិ មកធ្វើអាជីវកម្មនយោបាយក្នុងគោលដៅវាយប្រហារមកលើរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដើម្បីផលប្រយោជន៍នយោបាយរបស់ខ្លួន។ ដូចខ្ញុំព្រះករុណាខ្ញុំធ្លាប់បាន

លើកឡើងជារឿយៗមកហើយថា នេះមិនមែនជារឿងប្លែក និងថ្មីសម្រាប់កម្ពុជានោះទេ។ យុទ្ធសាស្ត្របែបនេះធ្លាប់ត្រូវបានគេយកមកប្រើរួចមកហើយនៅក្នុងប្រវត្តិសាស្ត្រនយោបាយរបស់កម្ពុជា។

(សេចក្ដីអធិប្បាយបន្ថែម)

*ដូចដែលគេទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅឆ្នាំ ១៩៧០ ក៏គេបានប្រើប្រាស់បញ្ហាព្រំដែន ដោយចោទប្រកាន់សម្ដេចព្រះនរោត្តម សីហនុ សម្ដេចឪ សម្ដេចតា សម្ដេចតាទួតនៃយើង ថាព្រះអង្គលក់ដីឱ្យវៀតណាមដែរ។ ដូច្នេះវាមិនមែនជាបញ្ហាថ្មីទេ។ តែឥឡូវនេះ ក៏មានចំណុចថ្មីសម្រាប់ដោះស្រាយចំពោះពួកអ្នកទាំងនេះ តាមវិធានការផ្លូវច្បាប់។*

ដូច្នេះ បើទោះបីជាមានការពន្យល់បំភ្លឺលើកនេះថែមទៀត ក៏ប្រហែល ជាអ្នកនយោបាយទាំងនោះនៅតែធ្វើជាមិនយល់ដដែលដែរ។ យ៉ាងណាក៏ដោយ គោលដៅចម្បងរបស់រាជរដ្ឋាភិបាលនាពេលនេះ គឺការផ្ដល់នូវការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ទាំងនៅក្នុង និងក្រៅប្រទេសឱ្យបានជ្រាបអំពីគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈមោះមុត និងក្នុងស្មារតីប្ដូរផ្ដាច់ ឥតងាករេក៏ដូចជាអំពីភាពហ្មត់ចត់ និងការទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាព្រំដែនរវាងកម្ពុជា និងវៀតណាម សំដៅជម្រះនូវភាពមិនច្បាស់លាស់ទាំងឡាយ នៅក្នុងកិច្ចការដ៏មានសារសំខាន់នេះ ក៏ដូចជារំលេចឱ្យឃើញផងដែរ នូវគោលបំណង និងផលប្រយោជន៍នយោបាយនានា ដែលលាក់បង្កប់នៅពីក្រោយការចោទប្រកាន់ និងការឃោសនាញុះញង់ដដែលៗឥតឈប់ឈរ ពាក់ព័ន្ធនឹងបញ្ហានេះ។

មុននឹងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណា (ខ្ញុំក៏)

សូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះជនរួមជាតិគ្រប់រូប ទាំងនៅក្នុង និងក្រៅប្រទេស ដែលមានសុភវិនិច្ឆ័យខ្ពស់ ហើយបានមើលឃើញយ៉ាងច្បាស់នូវសច្ចភាពនៃការរស់ឡើងវិញ និងការរីកចម្រើនរបស់ប្រទេសជាតិ ព្រមទាំងបាន ផ្តល់ជំនឿ និងការគាំទ្រដ៏ធំធេងចំពោះរាជរដ្ឋាភិបាលក្នុងការបំពេញបេសកកម្មជាប្រវត្តិសាស្ត្ររបស់ខ្លួននៅគ្រប់ដំណាក់កាល។

(សេចក្តីអធិប្បាយបន្ថែម)

*ហើយរយៈពេលចុងក្រោយ ក៏បានផ្ញើនូវសារយ៉ាងច្រើនគាំទ្រចំពោះរាជរដ្ឋាភិបាល ទៅលើវិធានការទាំងឡាយ ដែលរាជរដ្ឋាភិបាលបាននិងកំពុងធ្វើទៅលើបញ្ហាផែនទី ក៏ដូចជាបញ្ហាទាក់ទិនជាមួយនឹងបញ្ហាព្រំដែននេះ ដែលមានផ្ញើទាំងនៅក្នុងប្រទេស និងមកពីក្រៅប្រទេសផងដែរ។ អរគុណចំពោះអ្នកទាំងឡាយដែលបានគាំទ្រជាមួយនឹងទង្វើនេះ។*

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំសូមប្រសិទ្ធពរជ័យថ្វាយ ប្រគេននិងជូនសម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិកម្ពុជាគ្រប់រូប សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរព្រះគុណ និងសូមអរគុណ !*

ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ